ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៣ លេខ៤២២ ត្រីមាសទី០១ ឆ្នាំ២០២៣

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារធាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៩-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២០ ស្តីពី ការលុបឈ្មោះលោក **អម សុផាត** ពីក្របខ័ណ្ឌអភិបាល ឋានន្តរស័ក្តិ ឧត្តមអភិបាល ថ្នាក់ទី៣ មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ២៦៤៣

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **ឆៃបញ្ញា វីវ** (CHAIPANHA VIW) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **ឡៃ វីរ៉ា** (LAI VERA) ២៦៤៤

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **សំរេចវ៉ានិច រុចៈផន** (SUMREJWANICH RUCHAPON) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **តាន់ នីកឃី** (TAN NICKEY) ២៦៤៥

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **អាឆីវ៉ារ័ងឧបរោកសំភព** (ARCHEWARANGUBROK SOMPOP) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **លីម ចននី**(LIM JOHNNY) ២៦៤៦

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឆូសុងនឺន សារុត** (CHOSOONGNERN SARUT) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **ឆូ សាន់នី** (CHO SUNNY) ២៦៤៧

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឆៃយ៉ាសុផាណាត់ សុរិន** (CHAIYASUPPHANAT SURIN) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **ឆៃ ស្ទីវ** (CHAI STEVE) ២៦៤៨

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ស៊ីន យ៉ុងប៊ីង** (XUN. YONGBING) ជនជាតិចិន សញ្ជាតិចិន ២៦៤៩

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **នរ៉ាក់កានកន គ្រៀងសាក់** (NORAKARNKORN KRIENGSAK) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **ណរ ខេវីន** (NOR KAVIN) ២៦៥០

២០-១-២០២៣ -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឡេកឡែមឡាក់ ស៊ូរ៉ាឆៃ** (LEKLAEMLAK SURACHAI) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **ហ្ស៊ូ សាន់នី** (ZOO SUNNY) ២៦៥១

# ខ

| | | |
|---|---|---|
| ២០-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១២៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **ឆុនឡាណា អារ៉ាយ៉ា** (CHONLANA ARAYA) ជនជាតិថៃ សញ្ជាតិថៃ ដោយប្ដូរឈ្មោះជា **យ៉ា អាន់យ៉ា** (YA ANYA) | ២៦៥២ |
| ២០-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣០ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ខេមផេត ឆូកឆៃ** (KHEMPHET CHOKCHAI) ជនជាតិថៃ សញ្ជាតិថៃ ដោយប្ដូរឈ្មោះជា **តាំ ជែកខប់** (TAM JACOB) | ២៦៥៣ |
| ២០-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **សុផា ផាត់ឆារីន** (SUPHA PATCHARIN) ជនជាតិថៃ សញ្ជាតិថៃ ដោយប្ដូរឈ្មោះជា **សុផា ប៉ូឡា** (SUPA PAULA) | ២៦៥៤ |
| ២០-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣២ ស្ដីពី ការតែងតាំងនិងផ្ដល់ឋានៈឯកឧត្តម **លន់ សុផាត** ជាទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ | ២៦៥៥ |
| ២០-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣៣ ស្ដីពី ការតែងតាំងមុខតំណែងឯកឧត្តម **លីវ សុផាណ្ណារីន** ជាអនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២៦៥៦ |
| ២០-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣៤ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈជាទីប្រឹក្សា និងជាជំនួយការ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ១៣រូប | ២៦៥៧ |
| ២៣-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣៥ ស្ដីពី ការផ្ដល់គោរមងារ ឧកញ៉ា **ទៀ ណារ៉ាឫទ្ធ** ជាអ្នកឧកញ៉ា | ២៦៥៩ |
| ២៣-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣៦ ស្ដីពី ការផ្ដល់គោរមងារ លោកជំទាវ **មាស សុភារី** ជាឧកញ៉ា | ២៦៦០ |
| ២៣-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣៧ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ឈួយ ជំនាញ** ពីតំណាងអចិន្ត្រៃយ៍រង ឋានៈជា អគ្គរាជទូត នៃស្ថានតំណែងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា អមលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី ចូលប្រទេស | ២៦៦១ |
| ២៣-១-២០២៣ | -ព្រះរាជក្រឹត្យ នស/រកត/០១២៣/១៣៨ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឧត្តមសេនីយ៍ទោ **ស៊ុយ ច័ន្ទវិជ្ជនី** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ២៦៦២ |

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ២៧-២-២០២៣ | -អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ | ២៦៦៣ |
| ២-៣-២០២៣ | -អនុក្រឹត្យលេខ ៥០ អនក្រ.បក ស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ | ២៦៦៨ |
| ៣-២-២០២៣ | -អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា | ២៦៧៨ |
| ៣-២-២០២៣ | -អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ២៦៧៩ |
| ៣-២-២០២៣ | -អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៦៨១ |
| ៣-២-២០២៣ | -អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ២៦៨៣ |
| ៣-២-២០២៣ | -អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៦៨៥ |
| ៦-២-២០២៣ | -អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៦៨៧ |
| ៦-២-២០២៣ | -អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៦៩១ |
| ៦-២-២០២៣ | -អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែង និងតែងតាំងមន្ត្រីរាជការ | ២៧០៣ |
| ៦-២-២០២៣ | -អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែង | ២៧០៤ |
| ៦-២-២០២៣ | -អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពី ការលុបឈ្មោះ នាយទាហាន | ២៧០៥ |
| ៦-២-២០២៣ | -អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី | ២៧០៦ |
| ៦-២-២០២៣ | -អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្តីពី ការតែងតាំងជំនួយការក្រសួងធម្មការ និងសាសនា | ២៧០៧ |


### ២~សេចក្តីសម្រេច


| | | |
|---|---|---|
| ២៥-៤-២០២៣ | -សេចក្តីសម្រេចលេខ ៣១ សសរ ស្តីពី ការតែងតាំងអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តក្រចេះដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា | ២៧០៨ |
| ២៥-៤-២០២៣ | -សេចក្តីសម្រេចលេខ ៣២ សសរ ស្តីពី ការជ្រើសរើសពលទាហាន | ២៧១០ |


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ២៧-១២-២០២២ | -ប្រកាសលេខ ១០៣៥ សហវ.ប្រក ស្តីពី ការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនិងចំណាត់ថ្នាក់កម្មវិធី នៃមាតិកាថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ | ២៧១១ |
| ២៧-១២-២០២២ | -ប្រកាសលេខ ១០៣៧ សហវ.ប្រក ស្តីពី ការប្រគល់កាតព្វកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ | ២៧១៣ |
| ២៧-១២-២០២២ | -ប្រកាសលេខ ១០៣៨ សហវ.ប្រក ស្តីពី ការបែងចែកឥណទានចំណាយថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ | ២៧១៥ |

## ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


១៤-១២-២០២២ -ប្រកាសលេខ ៥៦៣ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ៉រដា (ខេមបូឌា) ហ៊្វូដ ឯ.ក បង្កើតរោងចក្រផលិតដំណាប់ផ្លែឈើ ២៧១៧

១៤-១២-២០២២ -ប្រកាសលេខ ៥៦៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេ.ខេ.អិម ហ្គាមេន បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ២៧២០

១៤-១២-២០២២ -ប្រកាសលេខ ៥៦៥ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យី ហ្ស៊ូ ហុង រី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ២៧២៣


## ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


១៧-៣-២០២២ -ប្រកាសលេខ ០១៨១ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៨១ រថ.អប្រក.លអ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ២៧២៦

១៧-៣-២០២២ -ប្រកាសលេខ ០១៨២ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៨២ រថ.អប្រក.លអ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ២៧៣០

១៧-៣-២០២២ -ប្រកាសលេខ ០១៨៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៨៤ រថ.អប្រក.លអ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ២៧៣៤

២៣-៣-២០២២ -ប្រកាសលេខ ០១៨៧ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៨៧ រថ.អប្រក.លអ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ២៧៣៨

២៣-៣-២០២២ -ប្រកាសលេខ ០១៨៨ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៨៨ រថ.អប្រក.លអ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ២៧៤២


## ៤~ទីស្ដីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌


១-២-២០២៣ -សេចក្ដីសម្រេចលេខ ០៦ កយ.សសរ/២៣ ស្ដីពី ការបង្កើតគណៈកម្មការកណ្ដាល និងអនុគណៈកម្មការនានា ដើម្បីទទួលបន្ទុកដឹកនាំរៀបចំសន្និបាតបូកសរុបការងារយុត្តិធម៌ឆ្នាំ២០២២ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ២០២៣ ២៧៤៦


## ៥~ទីស្ដីការរដ្ឋមន្ត្រីក្រសួងការពារជាតិ


២-៥-២០២៣ -សេចក្ដីសម្រេចលេខ ០៣៥ សសរ.កពជ ស្ដីពី ការប្រគល់បន្ថែមតួនាទីទទួលបន្ទុកផ្នែកច្បាប់លើមុខងារបច្ចុប្បន្ន ២៧៥២


## ៦~ទីស្ដីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍


១៣-១-២០២៣ -ប្រកាសលេខ ០៣៨ ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (SOP) សម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក ២៧៥៦

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១៧/០០៤ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦២២/៧០២ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៩
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : លុបឈ្មោះលោក **អម សុផារ៉ា** ពីក្របខ័ណ្ឌ អភិបាល ឋានន្តរសក្តិ ឧត្តមអភិបាល ថ្នាក់លេខ ៣ មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ចាប់ពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ ដោយសាមីជនទទួលមរណភាព ។

**មាត្រា២** : ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៥៥.២៣០១.១៧០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោកស្រី **ឆៃបញ្ញា វីវ** (CHAIPANHA VIW) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៤ នៅខេត្ត Nakhon Phanom ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **ឡៃ វីរ៉ា** (LAI VERA)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរសីហមុនី

ពរល.៤៣០១.១៥១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១៤៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **សំរេចវ៉ានិច រុចៈផន** (SUMREJWANICH RUCHAPON) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៧៤ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **តាន់ នីកឃី** (TAN NICKEY)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មដល់លោក **អាជីវ៉ារ៉ាំងឌុបប្រុកសំភព** (ARCHEWARANGUBROK SOMPOP) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៨៦ នៅខេត្ត Phuket ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **លីម ចននី** (LIM JOHNNY)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ភ.ល. ២៣០១.១៦៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឆូសុងនឺន សារុត** (CHOSOONGNERN SARUT) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៨៥ នៅខេត្ត Khon Kaen ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **ឆូ សាន់នី** (CHO SUNNY)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

១៧៧.២៣០១.១៤៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឆៃយ៉ាសុផាណាវ៉ាត់ សុរិន** (CHAIYASUPPHANAT SURIN) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦៨ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **ឆៃ ស្ទីវ** (CHAI STEVE)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

៣៧៨.៤៣០១.១៤៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១២៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ីន យ៉ុងប៊ីង** (XUN. YONGBING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៨០ នៅខេត្ត Yunnan សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១២៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ន៉រ៉ាក់ការនករន គ្រៀងសាក់** (NORAKARNKORN KRIENGSAK) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៦ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃ ដោយប្ដូរឈ្មោះជា **ណរ ខេវីន** (NOR KAVIN)។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

៣៧៧.២៣០១.១២៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសល្យបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឡេកឡែមឡាក់ ស៊ូរ៉ាឆៃ** (LEKLAEMLAK SURACHAI) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៨៥ នៅខេត្ត Nakhon Ratchasima ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **ហ៊្សូ សាន់នី** (ZOO SUNNY)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២៣០១.១៤៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

នស/រកត/០១២៣/១៤៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោកស្រី **ឆុនឡាណា អារ៉ាយ៉ា** (CHONLANA ARAYA) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៦ នៅខេត្ត Kamphaeng Phet ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **យ៉ា អាន់យ៉ា** (YA ANYA)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៣៩. ២៣០១. ១៤៧

នរោត្តមសីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានបច្ចុប្បន្នត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ខេមផេត ឆូកឆៃ** (KHEMPHET CHOKCHAI) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៨ នៅខេត្ត Chon Buri ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **តាំ ជ៉េកខប់** (TAM JACOB)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

៣៧. ២៣០១. ១៧០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោកស្រី **សុផា ផាត់ឆារីន** (SUPHA PATCHARIN) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៨៧ នៅខេត្ត Phayao ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **សុផា ប៉ូឡា** (SUPA PAULA)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពស. ២៣០១.១៣១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១៣៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០៦១៨ / ០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **លន់ សុផាត** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ពរក.២៣០១.១៣៤

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៣៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០៦១៨ /០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម /០៦៩៩ /០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងមុខតំណែងឯកឧត្តម **លីច សុផាណ្ណារីន** ជាអនុរដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ពរស.២៣០១.១៣៣

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១៣៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ នាថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភា លើកទី៦ នីតិកាលទី៦ នាថ្ងៃព្រហស្បតិ៍ ០៦រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបោះឆ្នោតជ្រើសតាំងឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប ជាអនុប្រធានទី១រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធាន រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈ ជាទីប្រឹក្សា និងជាជំនួយការ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ១៣រូប ៖

**ក-ទីប្រឹក្សា**

| | | | |
|---|---|---|---|
| ១- លោកជំទាវ **ជាម ច័ន្ទសុផាវ៉ា** | មានឋានៈស្មើ | រដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២- ឯកឧត្តម **សាយ គឹមអន** | មានឋានៈស្មើ | រដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣- ឯកឧត្តមបណ្ឌិត **ទេពចំរើន សាមីឌី** | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤- ឯកឧត្តមវេជ្ជបណ្ឌិត **ឈាន សុភ័ក្ត** | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥- ឯកឧត្តម **អ៊ិន សុភាព** | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៦- ឯកឧត្តម **យុត បូរឫទ្ធិ** | មានឋានៈស្មើ | អនុរដ្ឋលេខាធិការ | បន្ថែមលើមុខងារបច្ចុប្បន្ន |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ខ-ជំនួយការ**

| | | |
|---|---|---|
| ១- ឯកឧត្តមវេជ្ជបណ្ឌិត **ណាក់ ពេជ្រពិជ័យ** | មានឋានៈស្មើ អគ្គនាយក | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២- ឯកឧត្តម **ទូច ចន្នី** | មានឋានៈស្មើ អគ្គនាយក | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣- លោកជំទាវ **ខន្ធ ច័ន្ទសិរីវិជ្ជរ៉ា** | មានឋានៈស្មើ អគ្គនាយក | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤- ឯកឧត្តម **ញៀម ឥទ្ធា** | មានឋានៈស្មើ អគ្គនាយក | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៥- ឯកឧត្តម **រឹម ណូវ៉ាន់នី** | មានឋានៈស្មើ អគ្គនាយក | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៦- លោកជំទាវ **នូ ដាវី** | មានឋានៈស្មើ អគ្គនាយក | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៧- ឯកឧត្តម **គង់ សីលា** | មានឋានៈស្មើ អគ្គនាយក | |

**មាត្រា២ :** សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៣៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

ឧកញ៉ា ទៀ ណារ៉ាឌុទ្ធ

ជា

**អ្នកឧកញ៉ា**

នរោត្តម សីហមុនី

៣៩៧.៤៣០១-១៣៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/[illegible]

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោកជំទាវ **មាស សុភាវី**

ជា

**ឧកញ៉ា**

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២៣*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** បញ្ចប់មុខតំណែងឯកឧត្តម **ឈួយ ជំនាញ** ពីតំណាងអចិន្ត្រៃយ៍រង ឋានៈជា អគ្គរាជទូត នៃស្ថានតំណាងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា អមលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី ចូលប្រទេស។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរជ.២៣០១.-១៣៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២៣*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១៣៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់ឧត្តមសេនីយ៍ទោ **ស៊ុយ ច័ន្ទធិដ្ឋនី** អត្តលេខ ៧៣៥៩៣ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

[illegible].២៣០១.១៣៧៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២៣

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ

- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ១០០៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការផ្ទេរគណៈកម្មការ អភិរក្សនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍ផ្សោតទន្លេមេគង្គ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីតំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ ដើម្បីការពារនិងអភិរក្សសត្វផ្សោតដែលជាធនសម្បត្តិធម្មជាតិមានជីវិតដ៏ពិសិដ្ឋ ប្រកបដោយប្រសិទ្ធភាព សំដៅចូលរួមអភិវឌ្ឍវិស័យអេកូទេសចរណ៍ លើកកម្ពស់សេដ្ឋកិច្ចសង្គមនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងថែរក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ សម្រាប់ការរីកលូតលាស់នៃជីវចម្រុះ និងទ្រទ្រង់ការរស់នៅរបស់សត្វផ្សោត។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើតំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ ក្នុងខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៣ .-**

តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

## ជំពូកទី៣
## ការកំណត់តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ

**មាត្រា៤ .-**

តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គមានប្រវែង១២០(មួយរយម្ភៃ)គីឡូម៉ែត្រ ក្នុងនោះខេត្តស្ទឹងត្រែងមានប្រវែង៣៥(សាមសិបប្រាំ)គីឡូម៉ែត្រនិងខេត្តក្រចេះមានប្រវែង៨៥(ប៉ែតសិបប្រាំ)គីឡូម៉ែត្រ ដែលលាតសន្ធឹងចាប់ពីប៉ែកខាងក្រោមស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រែង ក្នុងខេត្តស្ទឹងត្រែង រហូតដល់ក្បាលកោះទ្រង់ក្នុងខេត្តក្រចេះ មានទំហំសរុប៦២១(ប្រាំមួយរយម្ភៃមួយ)គីឡូម៉ែត្រក្រឡា ត្រូវកំណត់ជាកន្លែងអភិរក្ស (តំបន់ស្នូលអចិន្ត្រៃយ៍) ទំហំ២១៦,៤(ពីររយដប់ប្រាំមួយក្បៀសបួន)គីឡូម៉ែត្រក្រឡា និងកន្លែងការពារ (តំបន់ស្នូលតាមរដូវកាល) ទំហំ៤០៤,៦(បួនរយបួនក្បៀសប្រាំមួយ)គីឡូម៉ែត្រក្រឡា ដោយផ្អែកលើទិន្នន័យវិទ្យាសាស្ត្រពាក់ព័ន្ធនឹងការរស់នៅ ការបន្លាស់ទី ការស្វែងរកចំណី និងការបន្តពូជរបស់សត្វផ្សោត។

**មាត្រា៥ .-**

តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គចែកចេញជាពីរកន្លែង៖

ក. កន្លែងអភិរក្សសត្វផ្សោត

១- កន្លែងអភិរក្សកោះសន្ទក់ កោះកូនសត្វ និងត្បូងខ្លា

កន្លែងអភិរក្សកោះសន្ទក់ កោះកូនសត្វ និងត្បូងខ្លាមានទំហំសរុប១៣៨,៥(មួយរយសាមសិបប្រាំបីក្បៀសប្រាំ)គីឡូម៉ែត្រក្រឡា លាតសន្ធឹងចាប់ពីចំណុចក្បាលកោះស្រឡាយក្នុងស្រុកសៀមបូកនិងក្រុងស្ទឹងត្រែង

ខេត្តស្ទឹងត្រែងរហូតដល់ក្បាលកោះតន្ទជ័យនិងក្បាលកោះរងាវ ក្នុងស្រុកសំបូរ ខេត្តក្រចេះ មានប្រវែង៣៧,៥(សាមសិបប្រាំពីរក្បៀសប្រាំ)គីឡូម៉ែត្រ។

២- កន្លែងអភិរក្សខ្សាច់ម្កាក់និងកោះផ្ដៅ

កន្លែងអភិរក្សខ្សាច់ម្កាក់និងកោះផ្ដៅមានទំហំសរុប៥៥,៥គីឡូម៉ែត្រក្រឡា លាតសន្ធឹងចាប់ពីក្បាលអន្លង់សំប៉ាននិងក្បាលអន្លង់ខ្សាច់ម្កាក់រហូតដល់ក្បាលកោះព្រាល ក្នុងស្រុកសំបូរ ខេត្តក្រចេះ មានប្រវែង៣២(សាមសិបពីរ)គីឡូម៉ែត្រ។

៣- កន្លែងអភិរក្សកាំពី

កន្លែងអភិរក្សកាំពីមានទំហំសរុប២២,៤(ម្ភៃពីរក្បៀសបួន)គីឡូម៉ែត្រក្រឡា លាតសន្ធឹងចាប់ពីចំណុចខាងក្រោមព្រែកគ្រៀងក្នុងស្រុកព្រែកប្រសព្វនិងស្រុកសំបូរ រហូតដល់ក្បាលកោះទ្រង់ក្នុងខេត្តក្រចេះ មានប្រវែង១២(ដប់ពីរ)គីឡូម៉ែត្រ។

ចំពោះកន្លែងអភិរក្សដែលស្ថិតនៅក្បែរច្រាំងទន្លេ ត្រូវរក្សាទុកចម្ងាយ១០០(មួយរយ)ម៉ែត្រពីមាត់ច្រាំងជាកន្លែងការពារ។

ខ. កន្លែងការពារសត្វផ្សោត

តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ ក្រៅពីកន្លែងអភិរក្ស ត្រូវបានកំណត់ជាកន្លែងការពារ។

ផែនទីនិងនិយាមកាតំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ទំហំនិងព្រំប្រទល់តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ ដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះអាចកែប្រែបានតាមការចាំបាច់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## ការការពារនិងការអភិរក្សសត្វផ្សោត

**មាត្រា៧ .-**

ហាមឃាត់សកម្មភាពក្នុងកន្លែងអភិរក្សសត្វផ្សោតដូចខាងក្រោម៖

១- ការធ្វើនេសាទគ្រប់ប្រភេទ។

២- ការធ្វើវារីវប្បកម្ម។

៣- ការធ្វើនាវាចរឆ្លងកាត់ដែលមានឧបករណ៍ត្រៀមធ្វើនេសាទ។

៤- ការធ្វើនាវាចរដែលមានល្បឿនលើសពី៣០(សាមសិប)គីឡូម៉ែត្រក្នុងមួយម៉ោង។

៥- ការតាំងទីលំនៅ។

៦- សកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ ជាពិសេសសត្វផ្សោត។

**មាត្រា៨ .-**

ហាមឃាត់ការធ្វើនេសាទក្នុងកន្លែងការពារសត្វផ្សោតដូចខាងក្រោម៖

១- ការធ្វើនេសាទដោយប្រើមងឬសន្ទូចរនង។

២- ការធ្វើនេសាទដោយឧបករណ៍នេសាទខ្នាតមធ្យមនិងខ្នាតធំ។

**មាត្រា៩ .-**

សកម្មភាពអនុញ្ញាតក្នុងតំបន់គ្រប់គ្រងសត្វផ្សោតដូចខាងក្រោម៖

១- ការធ្វើនេសាទដោយឧបករណ៍ខ្នាតតូចក្នុងកន្លែងការពារ លើកលែងមងឬសន្ទូចរនង។

២- ការទស្សនាសត្វផ្សោត។

៣- ការអភិវឌ្ឍអេកូទេសចរណ៍។

៤- ការសិក្សាស្រាវជ្រាវសេដ្ឋកិច្ចវិទ្យាសាស្ត្រ។

## ជំពូកទី៥
## ទណ្ឌកម្ម

**មាត្រា១០ .-**

បុគ្គលណាដែលបំពាននឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះត្រូវទទួលទណ្ឌកម្មរដ្ឋបាលនិង/ឬទណ្ឌកម្មផ្សេងទៀតស្រប តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

អនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារ សត្វផ្សោតទន្លេមេគង្គ និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះនិងអភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៣

## ផែនទីនិងនិយាមកាតំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥០ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់វិធាននិងនីតិវិធីនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅធានាឱ្យបាននូវ៖

- ប្រសិទ្ធភាព និងតម្លាភាពនៃការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ដើម្បីអភិវឌ្ឍវិស័យអចលនវត្ថុប្រកបដោយចីរភាព
- សមធម៌នៃផលប្រយោជន៍រវាងអ្នកអភិវឌ្ឍអចលនវត្ថុ និងអតិថិជន
- ការទាក់ទាញការវិនិយោគ និងបង្កើនទំនុកចិត្តដល់សាធារណជន
- ការរួមចំណែកទប់ស្កាត់ហានិភ័យនៅក្នុងវិស័យអចលនវត្ថុ
- ការរួមចំណែកទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យក្នុងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

បច្ចេកសព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

- **អ.ស.ហ.** សំដៅដល់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- **ន.អ.ច.** សំដៅដល់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- **អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណដែលចេញដោយ **ន.អ.ច.** ដើម្បីអនុញ្ញាតឱ្យអ្នកអភិវឌ្ឍអចលនវត្ថុប្រកបអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **មន្ទីរ** សំដៅដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត
- **លិខិតអនុញ្ញាតអាជីវកម្ម** សំដៅដល់លិខិតអនុញ្ញាតដែលចេញដោយមន្ទីរ ដើម្បីអនុញ្ញាតឱ្យអ្នកអភិវឌ្ឍអចលនវត្ថុប្រកបអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ស្របតាមលក្ខខណ្ឌដូចមានកំណត់ក្នុងអនុក្រឹត្យនេះ
- **អាជីវកម្មអភិវឌ្ឍអចលនវត្ថុ** សំដៅដល់សកម្មភាពពាណិជ្ជកម្ម ឬវិនិយោគគ្រប់ប្រភេទក្នុងគោលបំណងសាងសង់លំនៅឋាន អគារសហកម្មសិទ្ធិ ឬអភិវឌ្ឍដីឡូត៍សម្រាប់លក់ ឬជួល
- **បុគ្គលអភិវឌ្ឍអចលនវត្ថុ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

សម្រាប់លក់ ឬជួល

- **អគារសហកម្មសិទ្ធិ** សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់ ជាអាទិ៍ អគារខុនដូ អគារការិយាល័យ អគារផ្សារ និងអគារពហុមុខងារជាដើម
- **ជួល** សំដៅដល់ការជួលដី ឬអគាររបស់អ្នកអភិវឌ្ឍអចលនវត្ថុដែលមានរយៈពេលចាប់ពី ១០ (ដប់) ឆ្នាំឡើងទៅ និងស្របតាមបទប្បញ្ញត្តិជាធរមាន
- **គណនីអភិវឌ្ឍអចលនវត្ថុ** សំដៅដល់គណនីសម្រាប់ទទួលប្រាក់បង់គ្រប់ប្រភេទរបស់អតិថិជនក្រោមទម្រង់ជាគណនីចរន្ត ឬគណនីសន្សំ ដែលបើកដោយអ្នកអភិវឌ្ឍអចលនវត្ថុនៅធនាគារពាណិជ្ជណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **ការបញ្ចប់គម្រោង** សំដៅដល់គម្រោងអភិវឌ្ឍអចលនវត្ថុណាមួយដែលបានបញ្ចប់ការសាងសង់ ការលក់ ឬការជួលអស់ជាស្ថាពរ និងដោយមានការយល់ព្រមពី **ន.អ.ប.**។

## ជំពូកទី២

## ស្ថាប័នគ្រប់គ្រង

**មាត្រា៤.-**

**ន.អ.ប.** មានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥.-**

មន្ទីរបំពេញតួនាទី ជាសេនាធិការជូន **ន.អ.ប.** ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុតាមលក្ខខណ្ឌដូចមានចែងនៅក្នុងអនុក្រឹត្យនេះ។ តួនាទី និងភារកិច្ចរបស់មន្ទីរ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៣

## អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

**មាត្រា៦.-**

រាល់ការធ្វើអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ត្រូវមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពី **ន.អ.ប.**។

ក្នុងករណីចាំបាច់ **ន.អ.ប.** អាចប្រគល់ភារកិច្ចជូនមន្ទីរក្នុងការចេញលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុ តាមការកំណត់របស់ប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម មិនអាចជាកម្មវត្ថុនៃការលក់ ជួល ឬដាក់ធានាកាតព្វកិច្ចណាមួយបានឡើយ។

**មាត្រា៧.-**

អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុត្រូវបានបែងចែកជាប្រភេទដូចខាងក្រោម÷

- អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍលំនៅឋាន
- អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអគារសហកម្មសិទ្ធិ
- អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍដីឡូត៍។

**មាត្រា៨.-**

អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិ ត្រូវបានចែកចេញជា ២ (ពីរ) ប្រភេទដូចខាងក្រោម÷

- អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មប្រភេទ១÷ ផ្តល់ជូនបុគ្គលអភិវឌ្ឍអចលនវត្ថុទាំងឡាយណាដែលសាងសង់គម្រោងចប់ជាស្ថាពរទើបប្រកាសលក់ឬជួល
- អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២÷ ផ្តល់ជូនបុគ្គលអភិវឌ្ឍអចលនវត្ថុទាំងឡាយណាដែលសាងសង់គម្រោងបណ្តើរ និងប្រកាសលក់ ឬជួលបណ្តើរ។

**មាត្រា៩.-**

វិធាន និងនីតិវិធីលម្អិតនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

## ជំពូកទី៤

## កិច្ចដំណើរការអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

### ផ្នែកទី១

### កាតព្វកិច្ចរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ

**មាត្រា១០.-**

បុគ្គលអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ១ អាចដំណើរការប្រតិបត្តិការលក់ ឬជួល បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ការសាងសង់ជាស្ថាពរ។

បុគ្គលអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ អាចដំណើរការប្រតិបត្តិការលក់ ឬជួល បន្ទាប់ពីទទួលបានអាជ្ញាបណ្ណពី **ន.អ.ប.**។

**មាត្រា១១.-**

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មមានកាតព្វកិច្ចដូចខាងក្រោម÷

- ត្រូវធ្វើសកម្មភាពអាជីវកម្ម ស្របតាមលក្ខខណ្ឌអាជីវកម្មដែលបានកំណត់ក្នុងអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម។ រាល់ការផ្លាស់ប្តូរលក្ខខណ្ឌអាជីវកម្ម ត្រូវស្នើសុំគោលការណ៍ឯកភាពជាមុនពី **ន.អ.ប.** ឬមន្ទីរ
- ត្រូវអនុវត្តកាតព្វកិច្ចឱ្យបានពេញលេញ និងចប់សព្វគ្រប់ដូចមានកំណត់ក្នុងកិច្ចសន្យាលក់ទិញ ឬជួល ដោយអនុលោមតាមបទដ្ឋានជាធរមាន

- ត្រូវប្រើប្រាស់គំរូកិច្ចសន្យាលក់ទិញ ឬជួល និងឯកសារគាំទ្រផ្សេងទៀតដែលបានដាក់ជូនមក **ន.អ.ប.** ឬមន្ទីរ
- ត្រូវបំបែកក្បាលដីទៅតាមចំនួនលំនៅឋាន ឬដីឡូត៍ដែលត្រូវអភិវឌ្ឍ ស្របតាមលក្ខណៈបច្ចេកទេស និងលក្ខខណ្ឌតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច
- ត្រូវផ្ទេរកម្មសិទ្ធិលើអចលនវត្ថុជូនអ្នកទិញស្របតាមកិច្ចសន្យាលក់ទិញ
- ត្រូវផ្តល់របាយការណ៍មក **ន.អ.ប.** ឬមន្ទីរឱ្យបានត្រឹមត្រូវ និងទៀងទាត់ស្របតាមលក្ខខណ្ឌដូចមានកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិជាធរមាន
- ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ ឬសហការជាមួយក្រុមហ៊ុនដែលមានអាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ ក្រោយប្រគល់លំនៅឋាន ឬអគារសហកម្មសិទ្ធិជូនដល់អតិថិជនចាប់ពី ៥០ (ហាសិប) ភាគរយ នៃគម្រោងទាំងមូល
- ត្រូវរាយការណ៍មក **ន.អ.ប.** ឬមន្ទីរអំពីឈ្មោះក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុដែលសហការលក់អចលនវត្ថុរបស់គម្រោង
- ត្រូវអនុវត្តកាតព្វកិច្ចដូចមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌអនុគ្រោះ និងពេលវេលាគ្រប់គ្រាន់សម្រាប់អតិថិជនក្នុងការសម្រេចចិត្តលើកិច្ចសន្យាលក់ទិញ ឬជួល មុននឹងចុះហត្ថលេខា ឬផ្តិតមេដៃព្រមព្រៀង
- ត្រូវប្រតិបត្តិតាមបទប្បញ្ញត្តិជាធរមានផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចការពារសិទ្ធិអតិថិជន
- ត្រូវអនុវត្តកាតព្វកិច្ចផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី២
## ការផ្សាយពាណិជ្ជកម្ម

**មាត្រា១២.-**

ការផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍអចលនវត្ថុតាមគ្រប់រូបភាព ត្រូវបានហាមឃាត់ចំពោះគម្រោង ឬបុគ្គលទាំងឡាយណាដែលពុំទាន់មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មពី **ន.អ.ប.** ឬមន្ទីរ។

**មាត្រា១៣.-**

ត្រូវបានហាមឃាត់ជាដាច់ខាត ចំពោះការផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងអាជីវកម្មអភិវឌ្ឍអចលនវត្ថុក្នុងរូបភាពទុច្ចរិត បំភ័ន្តការពិត ឬលាក់បាំងព័ត៌មានណាមួយដែលនាំឱ្យមានការភ័ន្តច្រឡំ ឬធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ឬចាត់ចូលជាទង្វើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

## ផ្នែកទី៣
## កិច្ចសន្យាលក់ទិញ ឬជួលអចលនវត្ថុ

**មាត្រា១៤.-**

កិច្ចសន្យាលក់ទិញ ឬជួលអចលនវត្ថុ ត្រូវកំណត់លក្ខខណ្ឌ និងព័ត៌មានអប្បបរមាដូចខាងក្រោម÷

- ឈ្មោះបុគ្គលអភិវឌ្ឍអចលនវត្ថុ និងឈ្មោះអតិថិជនដោយបញ្ជាក់អំពីអត្តសញ្ញាណ និងអាសយដ្ឋានរបស់គូភាគីឱ្យបានច្បាស់ និងមានសាក្សីដឹងឮ
- ឈ្មោះគម្រោង ទីតាំង ទំហំ និងតម្លៃលក់ទិញ ឬជួលដែលបានព្រមព្រៀងគ្នា
- របៀប និងកាលវិភាគបង់ប្រាក់នៃកិច្ចសន្យាលក់ទិញ ឬជួល
- ទំហំពិត និងទំហំសរុបសម្រាប់អគារសហកម្មសិទ្ធិ
- កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ការសាងសង់
- ឈ្មោះធនាគារ ឈ្មោះគណនី និងលេខគណនីអភិវឌ្ឍអចលនវត្ថុ
- ទំហំទឹកប្រាក់នៃការផាកពិន័យចំពោះការបង់ប្រាក់យឺតយ៉ាវរបស់អតិថិជន ដែលមានទំហំសមាមាត្រទៅនឹងទំហំទឹកប្រាក់នៃការផាកពិន័យចំពោះការសាងសង់យឺតយ៉ាវរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ
- សិទ្ធិរបស់អតិថិជនពាក់ព័ន្ធទៅនឹងដី ឬលំហចំណែកឯកជន និងចំណែករួមសម្រាប់អគារសហកម្មសិទ្ធិ
- សិទ្ធិក្នុងការរំលាយកិច្ចសន្យារបស់គូភាគី
- កាតព្វកិច្ចក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធប្លង់រួម សម្រាប់គម្រោងអភិវឌ្ឍដីឡូត៍
- កាតព្វកិច្ចរបស់គូភាគីដែលទទួលបន្ទុកបង់ពន្ធប្រថាប់ត្រា និងបង់កម្រៃសេវាផ្សេងៗទៀត
- កាតព្វកិច្ចក្នុងការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ និងការទទួលខុសត្រូវក្នុងករណីមិនបានបំពេញកាតព្វកិច្ចនេះ
- ការធានាខុសត្រូវលើគុណភាព និងសុវត្ថិភាពសំណង់
- បញ្ជីសម្ភារៈបំពាក់នៅក្នុងលំនៅឋាន ឬអគារសហកម្មសិទ្ធិ
- ការធានាកាតព្វកិច្ចរបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ ក្នុងករណីដីអភិវឌ្ឍនោះជាប់បន្ទុក ត្រូវប្រកាសប្រាប់អតិថិជនអំពីក្បាលដីជាប់បន្ទុកផ្សេងៗ និងបញ្ជាក់លក្ខខណ្ឌអំពីការធានាការផ្ទេរកម្មសិទ្ធិស្របច្បាប់ បន្ទាប់ពីអតិថិជនបានអនុវត្តកាតព្វកិច្ចបង់ប្រាក់រួចរាល់។

**មាត្រា១៥.-**

រាល់ការចុះកិច្ចសន្យាលក់ទិញ ឬជួលអចលនវត្ថុ ត្រូវធ្វើឡើងរវាងអតិថិជន និងបុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណពី **ន.អ.ប.** ឬលិខិតអនុញ្ញាតអាជីវកម្មពីមន្ទីរ។

ក្នុងករណីអ្នកចុះកិច្ចសន្យាលក់ទិញ ឬជួលអចលនវត្ថុមិនមែនជាកម្មសិទ្ធិករ ឬអ្នកទទួលបានសិទ្ធិជួលអចិន្ត្រៃយ៍លើដីដែលជាកម្មវត្ថុនៃការអភិវឌ្ឍ ត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពី

កម្មសិទ្ធិករ ឬពីអ្នកទទួលបានសិទ្ធិជួលអចិន្ត្រៃយ៍ស្របច្បាប់លើដីនោះ ប៉ុន្តែការទទួលខុសត្រូវលើកាតព្វកិច្ចនៃកិច្ចសន្យាជាបន្ទុករបស់បុគ្គលអភិវឌ្ឍអចលនវត្ថុ។

### ផ្នែកទី៤

### ប្រាក់តម្កល់ធានាអាជីវកម្ម

**មាត្រា១៦.-**

បុគ្គលអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិដែលស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មប្រភេទ២ និងបុគ្គលអភិវឌ្ឍដីឡូត៍ ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្ម ដូចមានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

### ផ្នែកទី៥

### គណនីអភិវឌ្ឍអចលនវត្ថុ

**មាត្រា១៧.-**

បុគ្គលអភិវឌ្ឍអចលនវត្ថុ ត្រូវបើកគណនីអភិវឌ្ឍអចលនវត្ថុ ដើម្បីទទួលការបង់ប្រាក់គ្រប់ប្រភេទរបស់អតិថិជន តាមលក្ខខណ្ឌដូចមានកំណត់ក្នុងកិច្ចសន្យាលក់ទិញ ឬជួល។

គណនីអភិវឌ្ឍអចលនវត្ថុ ត្រូវស្ថិតនៅក្រោមការតាមដានជាប្រចាំពី **ន.អ.ប.** និងអាចត្រូវបានស្នើសុំបិទ លុះត្រាតែគម្រោងអភិវឌ្ឍអចលនវត្ថុនោះត្រូវបានបញ្ចប់ជាស្ថាពរ និងមានការអនុញ្ញាតពី **ន.អ.ប.**។

**មាត្រា១៨.-**

ការដកប្រាក់ពីគណនីអភិវឌ្ឍអចលនវត្ថុ ត្រូវបានអនុញ្ញាតក្នុងគោលបំណងនៃការអភិវឌ្ឍគម្រោងអភិវឌ្ឍលំនៅឋាន ឬអគារសហកម្មសិទ្ធិ ឬគម្រោងអភិវឌ្ឍដីឡូត៍នោះតែប៉ុណ្ណោះ។

### ផ្នែកទី៦

### ការផ្អាក ការបញ្ឈប់សកម្មភាពអាជីវកម្ម និងការបញ្ចប់គម្រោង

**មាត្រា១៩.-**

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មដែលមានបំណងផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឬបញ្ចប់គម្រោងត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរជាមុនមក **ន.អ.ប.** ឬមន្ទីរ។

វិធាន និងនីតិវិធីលម្អិតពាក់ព័ន្ធការផ្អាក ការបញ្ឈប់សកម្មភាពអាជីវកម្ម និងការបញ្ចប់គម្រោងត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**មាត្រា២០.-**

**ន.អ.ប.** មានសិទ្ធិផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មជាបណ្ដោះអាសន្ន ឬជាស្ថាពរ ក្នុងករណីពិនិត្យឃើញថា បុគ្គលអភិវឌ្ឍអចលនវត្ថុអនុវត្តផ្ទុយពីបទប្បញ្ញត្តិជាធរមាន។

**មាត្រា២១.-**

យន្តការគ្រប់គ្រងកិច្ចដំណើរការអាជីវកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ជំពូកទី៥**

**ការត្រួតពិនិត្យ**

**មាត្រា២២.-**

**ន.អ.ប.** ឬមន្ទីរមានសិទ្ធិចាត់មន្ត្រីជំនាញមានសមត្ថកិច្ច÷

- ស្រាវជ្រាវ និងទប់ស្កាត់រាល់សកម្មភាពអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលគ្មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម
- ត្រួតពិនិត្យសកម្មភាពអាជីវកម្មអភិវឌ្ឍអចលនវត្ថុដែលមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា២៣.-**

**ន.អ.ប.** មានសិទ្ធិចាត់មន្ត្រីជំនាញមានសមត្ថកិច្ចចុះត្រួតពិនិត្យការងារគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុរបស់មន្ទីរ។

**មាត្រា២៤.-**

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មត្រូវផ្ដល់កិច្ចសហការជាមួយមន្ត្រីជំនាញមានសមត្ថកិច្ច និងត្រូវផ្ដល់នូវរបាយការណ៍ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការកំណត់របស់ **ន.អ.ប.** ដើម្បីសម្រួលដល់កិច្ចដំណើរការនៃការត្រួតពិនិត្យ។

**មាត្រា២៥.-**

យន្តការត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

**ជំពូកទី៦**

**របាយការណ៍**

**មាត្រា២៦.-**

បុគ្គលអភិវឌ្ឍអចលនវត្ថុដែលទទួលបានអាជ្ញាបណ្ណ ត្រូវដាក់ជូន **ន.អ.ប.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានធ្វើសវនកម្មរួច យ៉ាងយូរក្នុងរយៈពេល ៣(បី)ខែ បន្ទាប់ពីបិទបញ្ជីនៃឆ្នាំសារពើពន្ធនីមួយៗ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.អ.ប.** និងរបាយការណ៍ផ្សេងទៀតដែលកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

## ជំពូកទី៧

## ការផ្សះផ្សាវិវាទ

**មាត្រា២៧.-**

ក្នុងករណីមានវិវាទពាក់ព័ន្ធនឹងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ភាគីណាមួយអាចដាក់ពាក្យបណ្តឹងទៅ **ន.អ.ប.** ដើម្បីសម្រុះសម្រួល និងផ្សះផ្សាវិវាទ មុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច លើកលែងតែរឿងព្រហ្មទណ្ឌ។

នីតិវិធីនៃការផ្សះផ្សាវិវាទ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

## ជំពូកទី៨

## ទោសប្បញ្ញត្តិ

**មាត្រា២៨.-**

បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និង/ឬ បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ត្រូវទទួលរងទោសទណ្ឌរដ្ឋបាល នូវវិធានការដូចខាងក្រោម÷

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមឃាត់ការធ្វើប្រតិបត្តិការ ឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មបណ្តោះអាសន្នពី ០៦(ប្រាំមួយ) ខែ ទៅ ០១(មួយ) ឆ្នាំ
- ដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម ឬលិខិតអនុញ្ញាតជាគោលការណ៍
- បង្កកគណនីអភិវឌ្ឍអចលនវត្ថុ
- បង្កកប្រាក់តម្កល់ធានាអាជីវកម្ម
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ
- ផាកពិន័យជាប្រាក់
- ចាត់វិធានការផ្សេងៗទៀតទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២៩.-**

វិធាន និងនីតិវិធីនៃការដាក់ទោសទណ្ឌរដ្ឋបាល និងការកំណត់អំពើល្មើស ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា៣០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មីនា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣១
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ ដំឡើងឋានន្តរស័ក្តិ **វរសេនីយ៍ឯក** ដល់វរសេនីយ៍ទោ **លី លាងឆេង** អត្តលេខ ៦៥៦៥៨ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១៣ កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៤៨ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនាឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា១.-** បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់**ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តបណីតារាម និងវត្តពោសុខារាម ឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចំណាយអស់ថវិកាសរុបចំនួន ៥០៥ ៣៩៧ ដុល្លារអាម៉េរិកកន្លងមក ដូចមានរាយនាមខាងក្រោម៖

១- លោក សេង សុផល
២- លោក ផាត់ កប
៣- លោក គាន់ លីហួត
៤- កញ្ញា ឆេង ធីតា
៥- លោក ចំរើន ប្រុសពៅ
៦- លោក នុត សុខងួន
៧- លោក កែវ សុវណ្ណឧត្តម
៨- លោក ជា សុជាវិទ្ធិ
៩- លោក សៀង ពុធថា

១០- លោក **ភួង ភិរុណ**

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ១៨៩ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយស្ថាបនាជាតិ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនាឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា១.** បំពាក់មេដាយ**មាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ២២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តបណីតារាម និងវត្តពោសុខារាម ឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចំណាយអស់ថវិកាសរុបចំនួន ២១១ ៩០៦ ដុល្លារអាម៉េរិក កន្លងមក ដូចមានរាយនាមខាងក្រោមៈ

១- លោក ថោង ពិស្សាវង្ស
២- លោក ថោង សុវណ្ណរតនា
៣- លោក ភិន រតនា
៤- លោក មៅ ប៉ូច
៥- លោក អេន មករា
៦- លោក ហៃ វុទ្ធី
៧- លោក ឃុយ ហេង

| | | |
|---|---|---|
| ៨- | លោក | សួន តារា |
| ៩- | លោក |ឃី ចន្ទារិទ្ធ |
| ១០- | លោក | គី សុធនសុក្រឹត្យ |
| ១១- | អ្នកស្រី | ពៅ វឌ្ឍនៈ |
| ១២- | លោក | ប៉ែន សុធា |
| ១៣- | លោក | យិន អនន្ត |
| ១៤- | លោក | គុល ស៊ីណាន |
| ១៥- | លោក | សារិន រដ្ឋា |
| ១៦- | លោក | គឹម ជូកេត |
| ១៧- | លោក | សូត្រ សុសិលា |
| ១៨- | លោក | អ៊ិច រិទ្ធ |
| ១៩- | លោក | សុខ ផានិត |
| ២០- | លោក | យឿម ធានី |
| ២១- | លោក | អាន ភក្រា |
| ២២- | លោក | វឌ្ឍ ផូនាថ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៖ ១៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

### សម្រេច

**មាត្រា១**.-បំពាក់មេដាយ**មុនីសារាភ័ណ្ឌ**តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន២៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តអង្គរយៀប ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកាចំនួន ២ ២៤៩ ៨៧៤ ដុល្លារអាម៉េរិកកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់**ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- | ឧបាសិកា | លី ហួន | សប្បុរសជន |
| ២- | លោក | ព្រំ ចន្ថា | សប្បុរសជន |
| ៣- | អ្នកស្រី | ឈីវ ហុង | សប្បុរសជន |
| ៤- | លោក | ទូច វុទ្ធី | សប្បុរសជន |
| ៥- | លោក | ឡុង សារុធ | សប្បុរសជន |
| ៦- | លោក | ជា សុខា | សប្បុរសជន |
| ៧- | ឧបាសិកា | ឡុង សុខងីម | សប្បុរសជន |
| ៨- | អ្នកស្រី | តេង មុនីនាថ | សប្បុរសជន |

៩- ឧបាសិកា ឈុន គឿន សប្បុរសជន

១០- ឧបាសក សាន់ សន សប្បុរសជន

១១- លោក ឡុង ហេង សប្បុរសជន

១២- លោក ស៊ឹម រដ្ឋា សប្បុរសជន

១៣- លោក ប៊ូ ប៊ុនថា សប្បុរសជន

១៤- លោក សាត សាមុត សប្បុរសជន

១៥- អ្នកស្រី អៀ ចន្ថា សប្បុរសជន

១៦- លោក អ៊ុង យ៉េត សប្បុរសជន

ខ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- លោក សម ជួន សប្បុរសជន

២- លោក អ៊ុក សុវិរៈ សប្បុរសជន

៣- អ្នកស្រី ស៊ឹម ថាវី សប្បុរសជន

៤- លោក ស៊ឹម ស៊ីណា សប្បុរសជន

៥- ឧបាសក ចក់ ផុន សប្បុរសជន

៦- លោក យង់ យ៉ារិទ្ធ សប្បុរសជន

៧- លោក ឈូ សុភាព សប្បុរសជន

៨- លោក ជា សុឃីម សប្បុរសជន

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ សុក្រ ១៣ កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

### សម្រេច

**មាត្រា១.** បំពាក់មេដាយ**ស្ថាបនាជាតិ**តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន ២៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តអង្គរយៀប ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកាចំនួន ២៧៥ ៣១៤ ដុល្លារអាម៉េរិកកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មាសស្ថាបនាជាតិ**

| | | |
|---|---|---|
| ១-ឧបាសក | ជា ជឹម | សប្បុរសជន |
| ២-ឧបាសក | សឿ មួន | សប្បុរសជន |
| ៣-ឧបាសក | សៀង ភឹន | សប្បុរសជន |
| ៤-ឧបាសក | ចាប យន់ | សប្បុរសជន |
| ៥-ឧបាសិកា | ភួង ផុន | សប្បុរសជន |
| ៦-ឧបាសក |ឃឹម រ៉ា | សប្បុរសជន |
| ៧-ឧបាសិកា | ជា សុគន | សប្បុរសជន |
| ៨-ឧបាសិកា | ប៉ែន ធឿន | សប្បុរសជន |

៩-ឧបាសិកា ប្រាក់ សេមលី សប្បុរសជន

១០-ឧបាសិកា ហ៊ុន ផេន សប្បុរសជន

១១-លោក វ៉ែន សុវណ្ណ សប្បុរសជន

១២-លោក នី វិចិត្រ សប្បុរសជន

១៣-លោក វាល់ សុងហ៊ី សប្បុរសជន

១៤-លោក ខុន មន្នីឧត្តម សប្បុរសជន

១៥-លោក ណៃ សុទ្ធទីវ៉ា សប្បុរសជន

១៦-លោក ឈីន សម្បត្តិ សប្បុរសជន

១៧-លោក ឆក សុងហៃ សប្បុរសជន

១៨-លោក រិទ្ធ សុធារ៉ា សប្បុរសជន

១៩-លោក ដួង ចាន់ណារ៉ូ សប្បុរសជន

២០-លោក រស់ សីហា សប្បុរសជន

២១-អ្នកស្រី ជិន សុគណា សប្បុរសជន

២២-លោក ផៃ អឿន សប្បុរសជន

២៣-លោក ផៃ សំអាត សប្បុរសជន

ខ-មេដាយ**ប្រាក់ស្ថាបនាជាតិ**

១-លោក គួត ប៊ុនរុង សប្បុរសជន

២-លោក ហាង្ស នាំប្រសិទ្ធិ សប្បុរសជន

៣-លោក សំ បូរ៉េត សប្បុរសជន

៤-លោក តាំង សេរីវុឌ្ឍីកា សប្បុរសជន

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

ថ្ងៃ សុក្រ ១៣កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ១២៤៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការ តែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.** បំពាក់មេដាយ**ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ៩៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តពោធិ៍អណ្តែត ឃុំព្រៃស្នៀត ស្រុកពាមរាំង ខេត្តព្រៃវែងកន្លងមក ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម៖

ក- មេដាយ**មាសស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ឡាច ប៊ុន្នី** | ព្រះគ្រូសូត្រស្តាំវត្តពោធិ៍អណ្តែត | បច្ច័យចំនួន | ១០,០០០ដុល្លារ |
| ២-ព្រះតេជគុណ | **អ៊ុម អឿ** | គង់នៅវត្តនន្ទមុន្នីរាជធានីភ្នំពេញ | បច្ច័យចំនួន | ១០,០០០ដុល្លារ |
| ៣-ឯកឧត្តម | **មាស សក្តិ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០,០០០ដុល្លារ |
| ៤-ឯកឧត្តម | **ឈាង សុវណ្ណារ៉ា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០,០០០ដុល្លារ |
| ៥-ឯកឧត្តម | **ផន គិរីវណ្ណា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០,០០០ដុល្លារ |
| ៦-ឯកឧត្តម | **ហាន់ សុវណ្ណ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០,០០០ដុល្លារ |
| ៧-ឧបាសិកា | **ទេព ឧត្តី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០,០០០ដុល្លារ |
| ៨-ឧបាសក | **ស៊ឹម សំអឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១០,០០០ដុល្លារ |

១០-លោកស្រី **ខៀវថង អមរ៉ា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១១-លោក **ស៊ុន រ័ត្ន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១២-លោក **ឡឿន ឧត្តមសេនីយ៍** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១៣-លោកស្រី **តាំង ហ្គេចយូរ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១៤-លោកស្រី **តាំង ហ្គេចស៊ាម** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១៥-លោក **ជុំសម វាសនា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១៦-លោក **ផុន តារិទ្ធ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១៧-លោក **ញ៉ឹក ស៊ីណា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១៨-លោក **ប៊ិច សុខ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
១៩-លោក **ស៊ាង វិចិត្រ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
២០-លោក **ផេង សម្ផស្ស** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
២១-លោក **ស្វ រិទ្ធីរ៉ាមុនី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
២២-លោក **សាំង ចន្ថា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
២៣-លោកស្រី **អឿ ស៊ីសត្ថា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០,០០០ដុល្លារ
២៤-លោក **ឈឿង គីមឡេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
២៥-លោក **ហ៊ឹម ម៉ាសិលា** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
២៦-លោក **សុន ដ្ឋិណាង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
២៧-លោក **ស្រេង សុខន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
២៨-លោកស្រី **សេង ហួន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
២៩-លោក **ប៉ាន់ សុវណ្ណឧត្តម** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
៣០-លោក **ហ៊ាន សុខចេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
៣១-លោក **ឈួ ប៊ុនលី** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
៣២-លោក **ហេង មណីកែវ** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
៣៣-លោកស្រី **ឈួ ម៉ុយឡេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
៣៤-លោក **ឈួ គុងហេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
៣៥-លោក **កែវ មណីពិសិដ្ឋ** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ
៣៦-លោកស្រី **ឌិត វណ្ណថារ៉េន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ១០,០០០ដុល្លារ

ខ- មេដាយ**ប្រាក់ស្ថាបនាជាតិ**

១-លោក **អឿន ម៉ារ៉ា** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥,០០០ដុល្លារ
២-លោក **ហ៊ុល ទូច** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥,០០០ដុល្លារ
៣-លោក **ប៉ាន់ សឿន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥,០០០ដុល្លារ
៤-លោក **ហេង រិទ្ធី** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥,០០០ដុល្លារ
៥-លោក **ម៊ិន សពញ្ញា** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥,០០០ដុល្លារ
៦-លោក **ស៊ិន ច័ន្ទកញ្ញា** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥,០០០ដុល្លារ
៧-ឧបាសក **សំរិត សិត** ប្រធានគណៈកម្មាធិការវត្តពោធិ៍អណ្ដែត ថវិកាចំនួន ៥,០០០ដុល្លារ
៨-ឧបាសក **គ្រោត ហាយ** ប្រធានអាចារ្យវត្តពោធិ៍អណ្ដែត ថវិកាចំនួន ៥,០០០ដុល្លារ

| | | | | |
|---|---|---|---|---|
| ៩-ឧបាសក | **កែ ស៊ុន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១០-ឧបាសិកា | **ម៉េងស៊ុន ឃីម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១១-លោកស្រី | **អៀ សារ៉ាន់** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១២-លោកស្រី | **ផាន់ ផាត់ស្រីយ៉ា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១៣-លោកស្រី | **មុត គន្ធី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១៤-លោក | **គង់វង្ស ជានិច្ច** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១៥-លោកស្រី | **ផុន មករា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១៦-លោក | **ជា ម៉ានិត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១៧-លោក | **ជីវ ហ៊ី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១៨-លោក | **ស៊ុន មុន្នី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ១៩-លោក | **អ៊ឹម បញ្ញា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ២០-លោក | **រស់ ឧត្តម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ២១-លោក | **ឃីម គឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ២២-លោក | **អ៊ឹម តូ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |
| ២៣-លោកស្រី | **ជា រតនា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥,០០០ដុល្លារ |

គ- មេដាយ**សិរីវឌ្ឍស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-ឧបាសក | **ថោង សេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ២-ឧបាសិកា | **ទូច ហៃ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ៣-ឧបាសិកា | **អោក សាវន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ៤-ឧបាសិកា | **ស្រ៊ុន ឃុន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ៥-ឧបាសក | **កង ទុន្ធី** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ៦-ឧបាសក | **ក្រោក រស់** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ៧-ឧបាសិកា | **ចាន់ សម្បត្តិ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ៨-ឧបាសិកា | **អន សៀង** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ៩-ឧបាសិកា | **គង់ ណេង** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១០-ឧបាសិកា | **រស់ សែម** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១១-ឧបាសិកា | **មុំ ដឹម** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១២-ឧបាសិកា | **ប៊ួយ ស្រី** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១៣-ឧបាសក | **ប៉ែន សេង** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្ល |
| ១៤-ឧបាសិកា | **ហ៊ា ទូច** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១៥-ឧបាសក | **ឃ្លោក តា** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្ល |
| ១៦-ឧបាសក | **ឡឹក យ៉ាន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១៧-ឧបាសក | **ហេង ជាវ** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១៨-លោក | **គង់ នួន** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ១៩-ឧបាសិកា | **ស្រៀង ផល្លី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៣,០០០ដុល្លារ |
| ២០-ឧបាសិកា | **យ៉េន ចឹម** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន | ៣,០០០ដុល្លារ |

២១-ឧបាសក **ចាប គី** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
២២-ឧបាសក **ជី ទី** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
២៣-លោក **ចក់ លុយ** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
២៤-ឧបាសិកា **ឆេង ឆេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
២៥-ឧបាសក **ឆង់ ម៉ៅ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣,០០០ដុល្លារ
២៦-ឧបាសិកា **ពិន យ៉ុម** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
២៧-ឧបាសក **ស្រៀន ស៊ីហ៊ាង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
២៨-ឧបាសិកា **ពិន ស៊ុំ** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
២៩-ឧបាសិកា **ហែម ឈេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣០-ឧបាសិកា **អ៊ុន ម៉ាន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣១-ឧបាសក **ឈន គីមឈាង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣២-ឧបាសិកា **អាន ស៊ីម** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣៣-លោកស្រី **ហ៊ី ធឿន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣៤-លោក **អាន ផុន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣៥-លោក **ខួន ហួត** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣៦-លោក **វណ្ណា ចិត្រា** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ
៣៧-លោកស្រី **ផៃ មុយឡេង** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៣,០០០ដុល្លារ

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៥ កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៦ ខែ មករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១២៨៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនាឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន២៤២រូប ដែលបានលះបង់កម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និងសមិទ្ធផលនានាជាច្រើនទៀត ស្ថិតនៅក្នុងឃុំព្រៃញ្ញៅ ស្រុកពារាំង ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ៦៨គ្រឿង ផ្តល់ជូន :**

១-ឧត្តមសេនីយ៍ត្រី **ស្លូ សៃ** អត្តលេខ៨៩១៦៨ ជំនួយការប្រធាននាយកដ្ឋានបុគ្គលិក
ចរិកាចំនួន ១០.០០០ ដុល្លារ

២-ឧត្តមសេនីយ៍ត្រី **ញឹក ដាលី** អត្តលេខ៨៨៨៨១ អនុប្រធាននាយកដ្ឋានអក្សរសម្ងាត់
ចរិកាចំនួន ១០.០០០ ដុល្លារ

៣-ឧត្តមសេនីយ៍ត្រី **ចាន់ ធីតា** អត្តលេខ០៥៤១៩ នាយការិយាល័យ នាយកដ្ឋានបុគ្គលិក
ចរិកាចំនួន ១០.០០០ ដុល្លារ

៤-ឧត្តមសេនីយ៍ត្រី **ខិន សុមករា** អត្តលេខ៥៥៨៧០ អនុប្រធាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ
ចរិកាចំនួន ១០.០០០ ដុល្លារ

៥-លោកស្រី **ចន សំអាង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

៦-ឧត្តមសេនីយ៍ទោ **ខា សណ្ដាប់** អត្តលេខ៥៦៦៥៣ ប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ ថវិកាចំនួន ១០.០០០ ដុល្លារ

៧-លោកស្រី **ហុង លក្ខិណា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

៨-លោក **ហាក់ សារុំ** មន្ទីរបរិស្ថានខេត្តកោះកុង ថវិកាចំនួន ១០.០០០ ដុល្លារ

៩-លោកស្រី **ហែម សុជាតិ** មន្ត្រីធនាគារជាតិនៃកម្ពុជា ថវិកាចំនួន ១០.០០០ ដុល្លារ

១០-អនុសេនីយ៍ឯក **ឆាង សុភក្ដី** អត្តលេខ៦៧៦២៦ នាយរងប៉ុស្តិ៍ ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល ថវិកាចំនួន ១០.០០០ ដុល្លារ

១១-លោក **ញឹម ប៉ូរ៉ា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

១២-លោក **ម៉ាន់ សារី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

១៣-លោក **កែវ សុវណ្ណ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

១៤-លោកស្រី **សៀង សុគន្ធី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

១៥-លោក **ឡុង នី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

១៦-លោក **អាត មួយអ៊ាង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

១៧-ឧត្តមសេនីយ៍ត្រី **កែវ វ៉េតមុន្នី** អត្តលេខ៧៥៧២៧ អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ថវិកាចំនួន ១០.០០០ ដុល្លារ

១៨-វរសេនីយ៍ឯក **ស្រេង ចិន្ដា** អត្តលេខ៧៨០៩៨ អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ ថវិកាចំនួន ១០.០០០ ដុល្លារ

១៩-វរសេនីយ៍ទោ **ហិម សុមិនា** អត្តលេខ៧៧៨៥៨ នាយរងការិយាល័យ អគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម ថវិកាចំនួន ១០.០០០ ដុល្លារ

២០-វរសេនីយ៍ទោ **នាង គុលា** អត្តលេខ៧៨១៨១ នាយរងការិយាល័យ អគ្គលេខាធិការដ្ឋាន ថវិកាចំនួន ១០.០០០ ដុល្លារ

២១-អនុសេនីយ៍ឯក **ស្រ៊ិន វិសាល** អត្តលេខ៨៣៤២២ នាយរងផ្នែក នាយកដ្ឋាននគរបាល ព្រហ្មទណ្ឌ ថវិកាចំនួន ១០.០០០ ដុល្លារ

២២-អនុសេនីយ៍ឯក **មុត លីនដា** អត្តលេខ៨៣៣៩៦ នាយរងផ្នែក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ថវិកាចំនួន ១០.០០០ ដុល្លារ

២៣-វរសេនីយ៍ត្រី **ស៊ឹម រុំ** អត្តលេខ៣៣៧៤១ មន្ត្រីនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ថវិកាចំនួន ១០.០០០ ដុល្លារ

២៤-អនុសេនីយ៍ឯក **សាន់ សុធន** អត្តលេខ៦៥៩៤០ មន្ត្រីនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ថវិកាចំនួន ១០.០០០ ដុល្លារ

២៥-អនុសេនីយ៍ត្រី **ឡាយ រដ្ឋធានី** អត្តលេខ៩៣៨០៣ មន្ត្រីស្នងការដ្ឋានហិរញ្ញកិច្ច និងភស្តុភារ ថវិកាចំនួន ១០.០០០ ដុល្លារ

២៦-អនុសេនីយ៍ត្រី **ឆា ម៉េងសេង** អត្តលេខ៩៥៩៤០ មន្ត្រីនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ថវិកាចំនួន ១០.០០០ ដុល្លារ

២៧-លោក **ខ៉េង យ៉ាឌឹន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

២៨-លោកជំទាវ ហ៊្ន សោភា សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
២៩-លោក ម៉ុង ហៃ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣០-លោក ឆោម ចន្ថា សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣១-លោក ប៉ែន ម៉ាន់មាសពិសិដ្ឋ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣២-វរសេនីយ៍ឯក សេង ចំរើន អត្តលេខ៦៤៧៦ អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ថវិកាចំនួន ១០.០០០ ដុល្លារ
៣៣-លោក គី ស្រួយ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣៤-អនុសេនីយ៍ឯក សាន វីរៈ អត្តលេខ៨៥៦៣០ នាយរងផ្នែក ស្នងការដ្ឋាននគរបាល រាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣៥-លោកស្រី ថន ដាណេ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣៦-លោកស្រី គាំង ខាន់គន្ធារី សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣៧-លោកស្រី អ៊ីង គីមជូ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣៨-លោកស្រី មិន សុវណ្ណមុនីនាថ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៣៩-លោក គោ ថវីរុង សប្បុរសជននៅខេត្តបាត់ដំបង ថវិកាចំនួន ១០.០០០ ដុល្លារ
៤០-លោក ហ៊ី ហៀត សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៤១-លោក សៅ សុខវិន្ធា សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៤២-អនុសេនីយ៍ទោ នីវ គំត្រា អត្តលេខ៨៧៦២១ នាយរងផ្នែក ស្នងការដ្ឋាននគរបាល ខេត្តព្រះសីហនុ ថវិកាចំនួន ១០.០០០ ដុល្លារ
៤៣-អនុសេនីយ៍ឯក យឹម ច័ន្ទតារា អត្តលេខ៨៧៦៨៨ នាយរងផ្នែក ស្នងការដ្ឋាននគរបាល ខេត្តព្រះសីហនុ ថវិកាចំនួន ១០.០០០ ដុល្លារ
៤៤-អនុសេនីយ៍ឯក ច័ន្ទ វីរៈ អត្តលេខ៨៧៦១៤ នាយរងផ្នែក ស្នងការដ្ឋាននគរបាល ខេត្តព្រះសីហនុ ថវិកាចំនួន ១០.០០០ ដុល្លារ
៤៥-វរសេនីយ៍ត្រី រាសី សុខា អត្តលេខ៨៣០៧៦ នាយផ្នែក នាយកដ្ឋានបុគ្គលិក ថវិកាចំនួន ១០.០០០ ដុល្លារ
៤៦-វរសេនីយ៍ឯក ខេង្ស ដារ៉ា អត្តលេខ៨៤៦០៣ អនុប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង ថវិកាចំនួន ១០.០០០ ដុល្លារ
៤៧-លោក គ្រៀល សោភ័ណ មន្ទីរសុខាភិបាលខេត្តព្រះសីហនុ ថវិកាចំនួន ១០.០០០ ដុល្លារ
៤៨-លោក គីន សុភា មន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន ថវិកាចំនួន ១០.០០០ ដុល្លារ
៤៩-លោក ស៊ុំ គួង មេឃុំព្រៃព្នៅ ថវិកាចំនួន ១០.០០០ ដុល្លារ
៥០-ឯកឧត្តម ហុង លឹម សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៥១-លោកជំទាវ សួយ សុមានិត សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៥២-លោក ម៉ៅ ន័រ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៥៣-លោកស្រី ប៊ី សុភាព សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៥៤-លោក ឈាង សោភ័ណ សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ
៥៥-លោកស្រី ថុន ចន្ថា សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

៥៦-លោកស្រី **ថុល ឆ៉ាត** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៥៧-លោក **ម៉ូ វណ្ណារិទ្ធ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៥៨-លោក **ហុក ឌីណា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៥៩-លោក **ជ្រីវ ប៉ោផេង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៦០-លោក **ឡុង ជីសេង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៦១-លោក **ហែម ហេម៉ា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៦២-លោកស្រី **ឡូ ឆាយអ៊ីង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៦៣-លោក **គីម សិរីវ៉ាន់** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៦៤-លោក **ជួប ម៉ាន់ឌី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.000 ដុល្លារ
៦៥-លោក **ម៉ិច អួន** ប្រធានការិយាល័យស្រុកពារាំង ថវិកាចំនួន ១០.000 ដុល្លារ
៦៦-លោក **ញឹម ខេត** នាយកសាលា ថវិកាចំនួន ១០.000 ដុល្លារ
៦៧-លោក **សេង គីមចន់** នាយកសាលា ថវិកាចំនួន ១០.000 ដុល្លារ
៦៨-លោក **ម៉ុំ ធីរិទ្ធ** គ្រូបង្រៀន ថវិកាចំនួន ១០.000 ដុល្លារ

**ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ៤៨គ្រឿង ផ្តល់ជូន :**

១-ឧត្តមសេនីយ៍ត្រី **អ៊ាំង ម៉ាន់ឡឿន** អត្តលេខ៩៣៥៨៨ អនុប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម
ថវិកាចំនួន ៥.000 ដុល្លារ

២-វរសេនីយ៍ត្រី **គង់ សុនីដា** អត្តលេខ៨៨៨១៤ ជំនួយការប្រធាននាយកដ្ឋានបុគ្គលិក
ថវិកាចំនួន ៥.000 ដុល្លារ

៣-វរសេនីយ៍ត្រី **ម៉េន ពិសិដ្ឋ** អត្តលេខ៩៣៨៧២ មន្ត្រីនាយកដ្ឋានបុគ្គលិក
ថវិកាចំនួន ៥.000 ដុល្លារ

៤-ឧត្តមសេនីយ៍ទោ **ឌុក សុផ្លា** អត្តលេខ០៥៣៦៦ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.000 ដុល្លារ

៥-ឧត្តមសេនីយ៍ទោ **ពត ចាន់នី** អត្តលេខ០៧០៤៨ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.000 ដុល្លារ

៦-ឧត្តមសេនីយ៍ទោ **សត ណាពេញ** អត្តលេខ០៨០២៨ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.000 ដុល្លារ

៧-ឧត្តមសេនីយ៍ទោ **សុង ហុង** អត្តលេខ០៦២៨២ ជំនួយការប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.000 ដុល្លារ

៨-ឧត្តមសេនីយ៍ទោ **ផេង ណារិទ្ធ** អត្តលេខ៣២១៤១ អនុប្រធាននាយកដ្ឋានគ្រប់គ្រង អាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.000 ដុល្លារ

៩-ឧត្តមសេនីយ៍ទោ **នួន ម៉ុន្នី** អត្តលេខ៦២៥៣១ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.000 ដុល្លារ

១០-ឧត្តមសេនីយ៍ទោ **សៅ ម៉ុនលាភ** អត្តលេខ៨៤៧៧៧ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.000 ដុល្លារ

១១-ឧត្តមសេនីយ៍ត្រី **ឆំ សុធីរ័ត្ន** អត្តលេខ៦៣១៩៥ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.០០០ ដុល្លារ

១២-ឧត្តមសេនីយ៍ត្រី **សេង ជាសុខ** អត្តលេខ០៩៧៧៨ នាយរងការិយាល័យ នាយកដ្ឋាន គ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.០០០ ដុល្លារ

១៣-ឧត្តមសេនីយ៍ត្រី **អ៊ុច ឈួន** អត្តលេខ០៥៩៨៧ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.០០០ ដុល្លារ

១៤-ឧត្តមសេនីយ៍ត្រី **នាង ឧប្បាន្លី** អត្តលេខ៣២១១៥ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.០០០ ដុល្លារ

១៥-ឧត្តមសេនីយ៍ត្រី **ជី សែ** អត្តលេខ០៩៨២៥ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.០០០ ដុល្លារ

១៦-ឧត្តមសេនីយ៍ត្រី **អ៊ុយ ហុន** អត្តលេខ០៦៧៤៨ អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ
ថវិកាចំនួន ៥.០០០ ដុល្លារ

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់លោក **ខាន់ ណារ៉េ**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **BVM ម៉ាក់ នីតា ភ្នំដូង** ស្ថិតនៅភូមិក្ដីដូង ឃុំក្ដីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ របស់លោក **ខាន់ ណារ៉េ** (**ម្ចាស់ស្ថានីយ**)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងសាងសង់ពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ

២. ប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ

៣. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ម៉ែត្រ ពី របងព្រំដីស្ថានីយ

៤. ត្រូវមានរបាំងការពារបំពង់ខ្យល់ប្រេងឥន្ធនៈ

៥. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ

៦. ត្រូវបំពាក់គន្លឹះអាសន្នរួម និងគន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ
៧. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៨. ត្រូវមានគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៩. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១០. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១១. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១២. ត្រូវសង់របងជញ្ជាំងធ្វើពីវត្ថុធាតុមិនឆាបឆេះ និងកំពស់អប្បបរមា ៣ម៉ែត្រ បាំងជិតនៅព្រំដីស្ថានីយដែលនៅជាប់នឹងព្រំដីលំនៅដ្ឋាន។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ក្រសួងរ៉ែ និង ថាមពល

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០១៨៨ រ៉ែ.អបក.ធអ..........ចុះថ្ងៃទី......០៣..........ខែ.....មីនា.....ឆ្នាំ២០២២................របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០១៨៨ រ៉ែ.អបក.ធអ ចុះថ្ងៃទី.....០៣.....ខែ..មីនា...........ឆ្នាំ២០២២...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ព្រហ....៣រោច...ខែ..ផល្គុន....ឆ្នាំឆ្លូវ ត្រីស័ក..ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.០៣.ខែ.មីនា....ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០៦ កយធ.សាសរ/២៣

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការកណ្តាល និងអនុគណៈកម្មការនានា ដើម្បីទទួលបន្ទុកដឹកនាំរៀបចំសន្និបាតបូកសរុបការងារយុត្តិធម៌ឆ្នាំ២០២២ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ២០២៣

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការកណ្តាល និងអនុគណៈកម្មការមួយចំនួន ដើម្បីដឹកនាំរៀបចំសន្និបាតបូកសរុបការងារយុត្តិធម៌ឆ្នាំ២០២២ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោមៈ

**ក-គណៈកម្មការកណ្តាលដឹកនាំអង្គសន្និបាត**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **កើត រិទ្ធ** | រដ្ឋមន្ត្រី | ប្រធាន |
| ២-លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
| ៣-ឯកឧត្តម | **ព្រហ្ម សិទ្ធត្រា** | រដ្ឋលេខាធិការ | សមាជិក |
| ៤-ឯកឧត្តម | **គឹម សន្តិភាព** | រដ្ឋលេខាធិការ | សមាជិក |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | **ឡុង នរិទ្ធ** | រដ្ឋលេខាធិការ | សមាជិក |
| ៦-ឯកឧត្តម | **ជីវ សុខហាក់** | រដ្ឋលេខាធិការ | សមាជិក |
| ៧-ឯកឧត្តម | **ជិន ម៉ាលីន** | រដ្ឋលេខាធិការ | សមាជិក |
| ៨-ឯកឧត្តម | **កេង សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | សមាជិក |
| ៩-ឯកឧត្តម | **អ៊ូ រ៉ាស៊ី** | រដ្ឋលេខាធិការ | សមាជិក |
| ១០-ឯកឧត្តម | **កែវ សុផល** | រដ្ឋលេខាធិការ | សមាជិក |
| ១១-ឯកឧត្តម | **សួរ ចាន់ធី** | រដ្ឋលេខាធិការ | សមាជិក |
| ១២-ឯកឧត្តម | **សួន វិសាល** | រដ្ឋលេខាធិការ | សមាជិក |
| ១៣-ឯកឧត្តម | **ខាន់ វណ្ណៈ** | រដ្ឋលេខាធិការ | សមាជិក |
| ១៤-លោកជំទាវ | **ប៉ែន សុមេធា** | រដ្ឋលេខាធិការ | សមាជិក។ |

គណៈកម្មការកណ្ដាលដឹកនាំអង្គសន្និបាត មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងសម្រេចលើខ្លឹមសារ និងប្រធានបទនៃអង្គសន្និបាត
- ពិនិត្យ និងសម្រេចលើកិច្ចដំណើរការនៃអង្គសន្និបាត
- ពិនិត្យ និងសម្រេចលើការងារផ្សេងទៀតពាក់ព័ន្ធនឹងការរៀបចំសន្និបាត ដែលស្នើឡើងដោយអនុគណៈកម្មការនានា។

**ខ-អនុគណៈកម្មការទទួលបន្ទុកការងារឡូជីស្ទីក**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **កែវ សុផល** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **អ៊ួង សុភារិទ្ធ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | **កើត សេកាណា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោក | **ស៊ី ពិសេដ្ឋ** | អគ្គលេខាធិការរង | សមាជិក |
| ៥-លោក | **ស៊ឹង សារ៉ាត** | អគ្គលេខាធិការរង | សមាជិក |
| ៦-លោកស្រី | **សួរ ដានី** | អគ្គលេខាធិការរង | សមាជិក |
| ៧-លោកស្រី | **សារឿន សុពណ៌** | អគ្គលេខាធិការរង | សមាជិក |
| ៨-លោកស្រី | **ហ៊ិន សុភាព** | អគ្គលេខាធិការរង | សមាជិក |
| ៩-លោក | **ជួន ចំរើន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១០-លោក | **ណុប វណ្ណៈ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១១-លោក | **ម៉ែន ចំណាន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១២-លោក | **ឈឹម សារ៉ែន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៣-លោកស្រី | **ឆាន់ ច័ន្ទលី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៤-លោក | **ចេង គឹមហ៊ាង** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥-លោកស្រី | **ម៉ឹង សំយ៉ាន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៦-លោក | **ឆាយ សុភាព** | អនុប្រធាននាយកដ្ឋាន | សមាជិក |

| | | | |
|---|---|---|---|
| ១៧-លោក | **កែវ ឧត្តម** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៨-លោក | **ចេង សុខមាន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៩-លោក | **អ៊ុន រតនា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២០-លោកស្រី | **ហែម ម៉ូលីកា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២១-លោក | **ឃឹម វ៉ាលីយ៉ា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២២-លោកស្រី | **ហឿង ដានី** | ប្រធានអង្គភាពលទ្ធកម្ម | សមាជិក |
| ២៣-លោកស្រី | **ឌី សុភល្យាណា** | ប្រធានការិយាល័យ | សមាជិក |
| ២៤-លោកស្រី | **ម៉េង ស្រីនួន** | ប្រធានការិយាល័យ | សមាជិក |
| ២៥-លោក | **មូ សុខជា** | ប្រធានការិយាល័យ | សមាជិក |
| ២៦-លោក | **អន ស៊ានភិរុន** | ប្រធានការិយាល័យ | សមាជិក |
| ២៧-លោក | **មាស កែវសិរីរដ្ឋ** | ប្រធានការិយាល័យ | សមាជិក |
| ២៨-លោកស្រី | **ផល ភក្តជា** | ប្រធានការិយាល័យ | សមាជិក |
| ២៩-លោក | **ហ៊ី តាប់ជីវ័ន្ត** | ប្រធានការិយាល័យ | សមាជិក |
| ៣០-លោក | **ថៃលាង អេង** | ប្រធានការិយាល័យ | សមាជិក |
| ៣១-លោក | **ស៊ឹម មករា** | អនុប្រធានការិយាល័យ | សមាជិក |
| ៣២-លោក | **អ៊ុត ចាន់សាវី** | មន្ត្រី | សមាជិក |
| ៣៣-លោក | **ឆ ប៊ុនហៀង** | មន្ត្រី | សមាជិក |
| ៣៤-លោក | **សៀន សុវិសាល** | មន្ត្រី | សមាជិក។ |

អនុគណៈកម្មការទទួលបន្ទុកការងារឡូជីស្ទីក មានភារកិច្ចដូចខាងក្រោម៖

- រៀបចំ និងចាត់ចែងលិខិតអញ្ជើញគណៈអធិបតី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកា ចូលរួមក្នុងសន្និបាត
- កំណត់ចំនួន និងសមាសភាពដែលត្រូវចូលរួមសន្និបាត
- រៀបចំទីកន្លែងសម្រាប់រៀបចំសន្និបាត
- រៀបចំ និងចាត់ចែងអាហារសម្រន់ និងអាហារផ្សេងៗទៀត ក្នុងពេលសន្និបាត
- បោះពុម្ពផ្លាកសញ្ញា ផ្លាកពាក់ ប័ណ្ណរថយន្ត សម្រាប់ជូនគណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គសន្និបាត
- រៀបចំសម្ភារៈចាំបាច់ផ្សេងៗ ដែលបម្រើឱ្យការរៀបចំសន្និបាត
- ទទួលបន្ទុកការងារពិធីការ និងការសម្របសម្រួលកិច្ចដំណើរការនៃសន្និបាត
- រៀបចំ និងគ្រប់គ្រងបញ្ជីវត្តមាន និងការចុះឈ្មោះរបស់គណៈអធិបតី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកា នៃអង្គសន្និបាត
- ចាត់ចែងរៀបចំ និងចែកឯកសារជូនដល់គណៈអធិបតី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកា ដែលចូលរួមក្នុងសន្និបាត
- ចាត់ចែងអញ្ជើញអ្នកសារព័ត៌មាន វិទ្យុ និងទូរទស្សន៍

- ចាត់ចែងការងារសន្តិសុខ និងសណ្ដាប់ធ្នាប់
- រៀបចំគម្រោងចំណាយផ្សេងៗ សម្រាប់បម្រើការងាររៀបចំសន្និបាត
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**គ-អនុគណៈកម្មការទទួលបន្ទុករៀបចំខ្លឹមសារ និងឯកសារ**

| | | | |
|---|---|---|---|
| ១-ឯកឧត្ដម | **ជិន ម៉ាលីន** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្ដម | **កែវ សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្ដម | **សួរ ចាន់ធី** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្ដម | **ខាន់ វណ្ណៈ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥-លោកជំទាវ | **ខៀវ សុផានី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៦-លោកជំទាវ | **ម៉ៅ តិរុណា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៧-លោកជំទាវ | **អ៊ឹង រីណា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៨-ឯកឧត្ដម | **កើត សេភាណ្ឌ** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គលេខាធិការ | អនុប្រធាន |
| ៩-ឯកឧត្ដម | **ផូច សំភី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | អនុប្រធានអចិន្ត្រៃយ៍ |
| ១០-ឯកឧត្ដម | **ប៉ែន ពេជ្រសាលី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ១១-ឯកឧត្ដម | **តាន់ហ៊ាង ដាវ័ណ្ណា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ១២-ឯកឧត្ដម | **យ៉ឹម ផារ៉ូត** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ១៣-ឯកឧត្ដម | **ជាម សត្យា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ១៤-ឯកឧត្ដម | **សៀ តុង** | អគ្គាធិការ | សមាជិក |
| ១៥-លោក | **សៀង គង់** | អគ្គនាយករង | សមាជិក |
| ១៦-លោក | **ច័ន្ទ សត្ថា** | អគ្គនាយករង | សមាជិក |
| ១៧-លោក | **ឡុច សុខលៀង** | អគ្គាធិការរង | សមាជិក |
| ១៨-លោកស្រី | **ជា ករុណា** | អគ្គនាយករង | សមាជិក |
| ១៩-លោក | **សេង ពុទ្ធី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២០-លោក | **ជួន ចំរើន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២១-លោក | **ពៅ វិបុល** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២២-លោកស្រី | **ស្មាន់ វណ្ណធីតា** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៣-លោក | **លី សុផាណា** | ប្រធាននាយកដ្ឋាន | សមាជិក |

| | | | |
|---|---|---|---|
| ២៤-លោក | **ភាន់ សុទ្ធម៉ូលីន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៥-លោក | **ទូ សារឡុង** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៦-លោក | **ឆាយ សុភាព** | អនុប្រធាននាយកដ្ឋាន | សមាជិក។ |

អនុគណៈកម្មការទទួលបន្ទុករៀបចំខ្លឹមសារ និងឯកសារ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំកម្មវិធី និងរបៀបវារៈនៃសន្និបាត
- រៀបចំប្រធានបទនៃកិច្ចពិភាក្សានៅក្នុងសន្និបាត
- រៀបចំរបាយការណ៍ និងរាយការណ៍ជូនអង្គសន្និបាតនូវលទ្ធផលការងារយុត្តិធម៌ឆ្នាំ២០២២ និងកំណត់ទិសដៅការងារអាទិភាពសម្រាប់ឆ្នាំ២០២៣
- ធ្វើការបូកសរុបលទ្ធផលនៃកិច្ចពិភាក្សា
- រៀបចំសុន្ទរកថាបើក និងសុន្ទរកថាបិទសន្និបាត ជូនឯកឧត្តមរដ្ឋមន្ត្រី
- រៀបចំសេចក្តីសម្រេចចិត្តរបស់អង្គសន្និបាត និងកំណត់ទិសដៅសម្រាប់អនុវត្តបន្ត
- រៀបចំកំណត់ហេតុនៃសន្និបាត និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃសន្និបាត ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ឃ-អនុគណៈកម្មការទទួលបន្ទុកដឹកនាំកិច្ចពិភាក្សា**

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការប្រចាំការ | ប្រធាន |
| ២-ឯកឧត្តម | **គឹម សន្តិភាព** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | **ជីវ សុខហាក់** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម | **គេង សុម៉ារិទ្ធ** | រដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម | **ខាន់ វណ្ណៈ** | រដ្ឋលេខាធិការ | សមាជិក |
| ៦-ឯកឧត្តម | **កើត សេកាណូ** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គលេខាធិការ | សមាជិក |
| ៧-ឯកឧត្តម | **ផ្លូង សំអី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ៨-ឯកឧត្តម | **ម៉ែន ពេជ្រសាលី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ៩-ឯកឧត្តម | **តាន់ហ៊ាង ដារ៉ាវ័ណ្ណ** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ១០-ឯកឧត្តម | **យ៉ែម ផារ៉ូត** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ១១-ឯកឧត្តម | **ជាម សត្យា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក | សមាជិក |
| ១២-ឯកឧត្តម | **សៀ តុង** | អគ្គាធិការ | សមាជិក |

១៣-ឯកឧត្តម **សំ ប្រជាមានិត** អគ្គលេខាធិការ នៃ ឧ.ក.ច សមាជិក។

អនុគណៈកម្មការទទួលបន្ទុកដឹកនាំកិច្ចពិភាក្សា មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំកិច្ចពិភាក្សាលើប្រធានបទនៃអង្គសន្និបាត
- សហការជាមួយអនុគណៈកម្មការទទួលបន្ទុករៀបចំខ្លឹមសារ និងឯកសារ ដើម្បីរាយការណ៍អំពីលទ្ធផលនៃកិច្ចពិភាក្សាជូនអង្គសន្និបាត
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ២.-**

អនុគណៈកម្មការនីមួយៗ ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនដើម្បីរៀបចំសកម្មភាពការងារ ស្របតាមភារកិច្ចរៀងៗខ្លួនដូចបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ និងសុំការយល់ព្រមពីគណៈកម្មការកណ្តាលដឹកនាំអង្គសន្និបាត។

អនុគណៈកម្មការនីមួយៗ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួនតាមការចាំបាច់។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានអង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១១កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣

រដ្ឋមន្ត្រី

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ ០៣៩ សសរ.កពស.

**សេចក្តីសម្រេច**

**ស្តីពី**

**ការប្រគល់បន្ថែមតួនាទីទទួលបន្ទុកផ្នែកច្បាប់លើមុខងារបច្ចុប្បន្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣១អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ

## សម្រេច

**ប្រការ១.-**

ត្រូវបានប្រគល់បន្ថែមតួនាទីទទួលបន្ទុកផ្នែកច្បាប់លើមុខងារបច្ចុប្បន្នជូននាយទាហាននៃកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម៖

១-ឧត្តមសេនីយ៍ឯក **ទ៉ា មុនី** សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ
២-ឧត្តមសេនីយ៍ឯក **ចោច ចាវរិទ្ធ** មេបញ្ជាការរង កងទ័ពជើងគោក
៣-ឧត្តមនាវីឯក **ទា គឹមគុល** មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងទឹក
៤-ឧត្តមសេនីយ៍ឯក **យ៉ាត ទូច** មេបញ្ជាការរង នាយឧទ្ទកាល័យ បញ្ជាការដ្ឋានអង្គរក្ស
៥-ឧត្តមសេនីយ៍ទោ **ធី ម៉េង** នាយករង វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ខ.ភ.ម
៦-ឧត្តមសេនីយ៍ទោ **សូ ស៊ីផាន** នាយករង វិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន
៧-ឧត្តមសេនីយ៍ទោ **ពីឌ វ៉ាន់ឌី** នាយករង ឧទ្ទកាល័យអគ្គបញ្ជាការដ្ឋាន
៨-ឧត្តមសេនីយ៍ទោ **សុខ រដ្ឋា** នាយករង អធិការដ្ឋាន
៩-ឧត្តមសេនីយ៍ទោ **គឹម សារ៉ាន់** នាយករង ទីចាត់ការហិរញ្ញវត្ថុ
១០-ឧត្តមសេនីយ៍ទោ **នាង សុវណ្ណា** នាយករង ទីចាត់ការផែនការ
១១-ឧត្តមសេនីយ៍ទោ **ប៊ុន លាង** នាយករង ទីចាត់ការបច្ចេកទេស
១២-ឧត្តមសេនីយ៍ទោ **តឿក គឹមសុង** នាយករង ទីចាត់ការសុខាភិបាល
១៣-ឧត្តមសេនីយ៍ទោ **ម៉ី ចាន់ថេរៈ** នាយករង ទីចាត់ការការពារគីមីសាស្ត្រ
១៤-ឧត្តមសេនីយ៍ទោ **ឡេង ប៊ុនធឿន** នាយករង ទីចាត់ការបំពាក់អក្ខរៈ
១៥-ឧត្តមសេនីយ៍ទោ **វ៉េន មុន្នីរ័ត្ន** នាយករង ទីចាត់ការការងារព្រំដែន
១៦-ឧត្តមសេនីយ៍ទោ **សេង សំណាង** នាយករង ទីចាត់ការបុគ្គលិក
១៧-ឧត្តមសេនីយ៍ទោ **ជា គឹមហួរ** នាយករង ទីចាត់ការចលនូប្បត្ថម្ភ
១៨-ឧត្តមសេនីយ៍ទោ **ចៅ សេរី** នាយករង ទីចាត់ការអភិវឌ្ឍន៍
១៩-ឧត្តមសេនីយ៍ទោ **ប្រាក់ ប៊ុនថង** នាយករង ទីចាត់ការហ្វឹកហ្វឺន
២០-ឧត្តមសេនីយ៍ទោ **នាង សុជីវ** ស្នងការ ស្នងការដ្ឋានកសាងកម្លាំង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
២១-ឧត្តមសេនីយ៍ទោ **សឹង សុខន** មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម
២២-ឧត្តមសេនីយ៍ទោ **តាន់ សុផៃ** មេបញ្ជាការរង បញ្ជាការដ្ឋានរថក្រោះ
២៣-ឧត្តមសេនីយ៍ទោ **ហេង មករា** នាយសេនាធិការរង កងទ័ពជើងគោក
២៤-ឧត្តមសេនីយ៍ទោ **កែប ម៉ារ៉ាឌី** មេបញ្ជាការរង យោធភូមិភាគទី១
២៥-ឧត្តមសេនីយ៍ទោ **ឈួន ផាត** មេបញ្ជាការរង យោធភូមិភាគទី២
២៦-ឧត្តមសេនីយ៍ទោ **សេង ធារិន** មេបញ្ជាការរង នាយសេនាធិការ យោធភូមិភាគទី៥
២៧-ឧត្តមសេនីយ៍ទោ **អ៊ូ សាម៉ន** នាយសេនាធិការរង មេបញ្ជាការមូលដ្ឋានពោធិចិនតុង កងទ័ពជើងអាកាស
២៨-ឧត្តមសេនីយ៍ទោ **កង សុផានី** មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានការពារអាកាស
២៩-ឧត្តមសេនីយ៍ទោ **សុខ ធារ៉ា** មេបញ្ជាការរង កងពលធំអន្តរាគមន៍លេខ២
៣០-ឧត្តមសេនីយ៍ទោ **សួយ ណារិទ្ធ** មេបញ្ជាការរង កងពលតូចលេខ៧០
៣១-ឧត្តមសេនីយ៍ទោ **ជា សារ៉ាត់** នាយករង សាលានាយទាហានសកម្ម
៣២-ឧត្តមសេនីយ៍ត្រី **អាង បូរ៉ា** នាយករង មជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា
៣៣-ឧត្តមសេនីយ៍ត្រី **ទេព ចន្ទ្រា** នាយករង ទីចាត់ការឃោសនាព័ត៌មាន
៣៤-ឧត្តមសេនីយ៍ត្រី **ប្រាក់ ចន្ធី** នាយករង វិទ្យាស្ថានទ័ពជើងគោក

៣៥-ឧត្តមសេនីយ៍ត្រី **នៅ ស៊ីណា** មេបញ្ជាការរង បញ្ជាការដ្ឋានកាំភ្លើងធំ
៣៦-ឧត្តមសេនីយ៍ត្រី **ញ៉ៀម សុបញ្ញាធី** មេបញ្ជាការរង យោធភូមិភាគពិសេស
៣៧-ឧត្តមសេនីយ៍ត្រី **ជិន ហៀង** មេបញ្ជាការរង យោធភូមិភាគទី៣
៣៨-ឧត្តមសេនីយ៍ត្រី **ឡេង ថារិទ្ធ** នាយសេនាធិការរង យោធភូមិភាគទី២
៣៩-ឧត្តមសេនីយ៍ត្រី **គង ប៊ុនធឿន** នាយសេនាធិការរង យោធភូមិភាគទី៤
៤០-ឧត្តមសេនីយ៍ត្រី **ហូ តូរិទ្រ** នាយសេនាធិការរង យោធភូមិភាគទី៥
៤១-ឧត្តមសេនីយ៍ត្រី **ហ៊ឹម ហាប់** មេបញ្ជាការរង កងពលធំអន្តរាគមន៍លេខ៣
៤២-ឧត្តមសេនីយ៍ត្រី **កែវ រឿន** មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ១
៤៣-ឧត្តមសេនីយ៍ត្រី **ត្រ ឆាវិន** មេបញ្ជាការរង កងពលតូចដឹកជញ្ជូនលេខ៩០
៤៤-ឧត្តមសេនីយ៍ត្រី **ឡុង ឥន** មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ២១
៤៥-ឧត្តមសេនីយ៍ត្រី **សេស យ៉ុង** មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៣១
៤៦-ឧត្តមសេនីយ៍ត្រី **ស៊ឹម សុខា** មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៤២
៤៧-ឧត្តមសេនីយ៍ត្រី **វ៉ាន់ ដារ៉ាសិទ្ធិ** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងស្ទឹងត្រែង
៤៨-ឧត្តមសេនីយ៍ត្រី **គោត ចំរើន** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងព្រះសីហនុ
៤៩-ឧត្តមសេនីយ៍ត្រី **ប៉ាង ស** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ធំ
៥០-ឧត្តមសេនីយ៍ត្រី **ឥក ផាណ្ណា** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងព្រៃវែង
៥១-ឧត្តមសេនីយ៍ត្រី **ឌុច ដួន** នាយក សាលាពលទាហានទី៥
៥២-វរសេនីយ៍ឯក **ឡាង ពៅ** នាយករង សាលាពលទាហានទី១
៥៣-វរសេនីយ៍ឯក **សោម ហឿន** នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញការពារព្រំដែន
៥៤-វរសេនីយ៍ឯក **ឈឿ វណ្ណឌី** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកណ្តាល
៥៥-វរសេនីយ៍ឯក **សេម ផាត់** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី
៥៦-វរសេនីយ៍ឯក **ឈួន សត្រា** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ
៥៧-វរសេនីយ៍ឯក **ចាប សារឿន** មេបញ្ជាការរង នាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងតាកែវ
៥៨-វរសេនីយ៍ឯក **ស៊ុម ហឿន** មេបញ្ជាការរង នាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងកែប
៥៩-វរសេនីយ៍ឯក **ភាព កុសល** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង
៦០-វរសេនីយ៍ឯក **វ៉ា ញ៉ៅញ៉ៃ** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងសៀមរាប
៦១-វរសេនីយ៍ឯក **លាស់ ណាម** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងព្រះវិហារ
៦២-វរសេនីយ៍ឯក **ហូ ប៊ុនធី** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ
៦៣-វរសេនីយ៍ឯក **ហែម មារិទ្ធ** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងរតនគិរី
៦៤-វរសេនីយ៍ឯក **គោយ លិអង** មេបញ្ជាការរង នាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងបាត់ដំបង
៦៥-វរសេនីយ៍ឯក **កុល ចាន់ដារ៉ា** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងពោធិ៍សាត់
៦៦-វរសេនីយ៍ឯក **កែវ ស៊ីថា** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ
៦៧-វរសេនីយ៍ឯក **អៀង ប៊ុនថេង** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងប៉ៃលិន
៦៨-វរសេនីយ៍ឯក **ឃូ សុផាន់** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង
៦៩-វរសេនីយ៍ឯក **ជុំ ពៅ** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំពង់ចាម
៧០-វរសេនីយ៍ឯក **ឡាំ ឧទ្ធី** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងត្បូងឃ្មុំ
៧១-វរសេនីយ៍ឯក **ប្រាក់ សុខុម** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងស្វាយរៀង
៧២-វរសេនីយ៍ឯក **ដូ អេង** មេបញ្ជាការរង បញ្ជាការដ្ឋានទ័ពពិសេស
៧៣-វរសេនីយ៍ឯក **ចាន់ សែន** មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ១៤

| | | |
|---|---|---|
| ៧៤-វរសេនីយ៍ឯក | **ឯម ខាសនា** | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៤១ |
| ៧៥-វរសេនីយ៍ឯក | **សាលួត ឃាង** | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៥១ |
| ៧៦-វរសេនីយ៍ឯក | **សំ ផុង** | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៥២ |
| ៧៧-វរសេនីយ៍ឯក | **ជួប មេត្តា** | មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៥៣ |
| ៧៨-វរសេនីយ៍ឯក | **ហាក់ សីលា** | នាយរងការិយាល័យបុគ្គលិក កងទ័ពជើងអាកាស |
| ៧៩-វរសេនីយ៍ឯក | **មាស ចិន្តា** | ជំនួយការ ទីចាត់ការកលយុទ្ធ |
| ៨០-វរសេនីយ៍ទោ | **គង់ ស៊ី** | នាយរង ការិយាល័យបុគ្គលិក បញ្ជាការដ្ឋានបញ្ជូនសារ |
| ៨១-វរសេនីយ៍ទោ | **ពុត សាគុណា** | នាយផ្នែកវិន័យទណ្ឌកម្ម ការិយាល័យទី១ កងទ័ពជើងគោក |
| ៨២-វរសេនីយ៍ទោ | **គុំ ចេស្តា** | ជំនួយការមេបញ្ជាការយោធភូមិភាគ យោធភូមិភាគពិសេស |
| ៨៣-វរសេនីយ៍ទោ | **ហ៊ិន ខចិត្រ** | នាយលេខាធិការដ្ឋានតំបន់ប្រតិបត្តិការសឹករងក្រចេះ |
| ៨៤-វរសេនីយ៍ទោ | **ឃួន សុចន្ធី** | នាយសេនាធិការរង តំបន់ប្រតិបត្តិការសឹករងកំពត |
| ៨៥-វរសេនីយ៍ត្រី | **ភ័ណ្ឌ សុផល** | នាយរងការិ.គ្រប់គ្រងធានា នាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច |
| ៨៦-វរសេនីយ៍ត្រី | **ម៉ុង វណ្ណា** | នាយសេនាធិការរង កងពលតូចអន្តរាគមន៍លេខ១២៨ |

**ប្រការ២ .–**

នាយទាហានទទួលបន្ទុកផ្នែកច្បាប់ មានភារកិច្ចៈ

-ជំនួយការផ្នែកច្បាប់ ប្រចាំអង្គភាព

-ជាសេនាធិការឱ្យមេបញ្ជាការអង្គភាពពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្ត

-ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តដល់យោធិនក្នុងអង្គភាព

-ចូលរួមប្រជុំនិងចូលរួមសិក្ខាសាលាលើការងារច្បាប់តាមការអញ្ជើញរបស់នាយកដ្ឋាននីតិកម្មក្រសួងការពារជាតិ។

**ប្រការ៣ .–**

-សេចក្តីសម្រេចលេខ ០១៤.សសរ.កពជ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩

-សេចក្តីសម្រេចលេខ ០៥១.សសរ.កពជ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩

-សេចក្តីសម្រេចលេខ ០៤៣.សសរ.កពជ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

-សេចក្តីសម្រេចលេខ ០៥៥.សសរ.កពជ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០

ស្តីពីការប្រគល់បន្ថែមតួនាទីទទួលបន្ទុកផ្នែកច្បាប់លើមុខងារបច្ចុប្បន្ន ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .–**

អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន មេបញ្ជាការកងឯកភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ខែ...ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ–បាញ់**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់
- ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាននៃ ខ.ភ.ម
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០៣៨ ប្រក

ថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣

# ប្រកាស
## ស្តីពី
## ការដាក់ឲ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) សម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## និងជាប្រធានគណៈកម្មការអន្តរក្រសួង គ.អ.ច.ទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញសេចក្តីសម្រេចលេខ ០១ សសរ ចុះថ្ងៃទី ៤ ខែមករា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស "គ.អ.ច.ទ"
- យោងតាមភាពចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១.**_

ប្រកាសនេះមានគោលបំណងដាក់ឲ្យអនុវត្ត "នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP) សម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក" ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីផ្តល់ភាពងាយស្រួលដល់សមត្ថកិច្ច និងកាត់បន្ថយភាពស្មុគស្មាញរបស់ទេសចរបើកបរដោយខ្លួនឯងក្នុងពេលឆ្លងកាត់ការត្រួតពិនិត្យនៅតាមច្រកទ្វារព្រំដែននៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីពង្រឹងភាពទាក់ទាញនៃវិស័យទេសចរណ៍បើកបរដោយខ្លួនឯង។

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣._**

ប្រកាសនេះនិរាករប្រកាស ដូចខាងក្រោម៖

- ប្រកាសលេខ ០៣០ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្ដីពីការដាក់ឲ្យអនុវត្តវិធានសុវត្ថិភាព និងវិធានសម្រួលការធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោករបស់គណៈកម្មការអន្តរក្រសួង គ.អ.ច.ទ
- ប្រកាសលេខ ០៣៦ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ស្ដីពីការដាក់ឲ្យអនុវត្តវិធានសុវត្ថិភាព និងវិធានសម្រួលការធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោករបស់គណៈកម្មការអន្តរក្រសួង គ.អ.ច.ទ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស និងលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**
**និងជាប្រធានគណៈកម្មការអន្តរក្រសួង គ.អ.ច.ទ**

**ថោង ខុន**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចឯកឧត្តមលោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

ប្រកាសលេខ...០៣៩.ប្រក....

ចុះថ្ងៃទី...១៣..... ខែ...មករា...... ឆ្នាំ...២០២៣

ស្តីពី

ការដាក់ឲ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា (SOP)

សម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក

# នីតិវិធី

# ប្រតិបត្តិស្តង់ដារអប្បបរមា

# សម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯង

# តាមផ្លូវគោក

# Minimum Standard Operating Procedure

# on

# Self-Drive

# Tourism in

# CAMBODIA

ឆ្នាំ២០២៣

## មាតិកា

១. សេចក្តីផ្តើម
២.និយមន័យទេសចរបើកបរដោយខ្លួនឯង
៣. គោលបំណង និងវិសាលភាព
៤.បញ្ញត្តិទូទៅនៃការយកមធ្យោបាយធ្វើដំណើរចូលបណ្តោះអាសន្ននិងចេញទៅវិញ
៤.១. ការអនុញ្ញាត
៤.២. រយៈពេលកំណត់
៤.៣. ការពន្យារពេលចេញទៅវិញ
៤.៤. ការពិន័យ
៤.៥. លក្ខខណ្ឌនៃការប្រើប្រាស់
៥. ភារកិច្ចរបស់ភ្ញៀវទេសចរបើកបរដោយខ្លួនឯង
៥.១. ការបំពេញលក្ខខណ្ឌសម្រាប់សមត្ថកិច្ចគយនិងរដ្ឋាករកម្ពុជា
៥.២. ការបំពេញលក្ខខណ្ឌសម្រាប់ការចូលចេញ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
៥.៣. ការអនុវត្តវិធានសុខាភិបាល
៥.៤. ការអនុវត្តវិធានណែនាំនានាក្នុងពេលធ្វើដំណើរទេសចរណ៍
៥.៥. ការប្រតិបត្តិសំខាន់ៗក្នុងពេលបើកបរ
៥.៦. លេខទំនាក់ទំនងក្នុងគ្រាអាសន្ន
៦. គោលដៅទេសចរណ៍ និងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍
៧. សេចក្តីសន្និដ្ឋាន
៨. តារាងសង្ខេបអំពីទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក

**១. សេចក្តីផ្តើម**

ការធ្វើដំណើរ និងទេសចរណ៍ដោយការបើកបរដោយខ្លួនឯងត្រូវបានចាត់ទុកថាជាផ្នែកដ៏សំខាន់នៃវិស័យទេសចរណ៍ទាំងក្នុងតំបន់និងពិភពលោក។ ប៉ុន្តែវិបត្តិសកលនៃជំងឺកូវីដ-១៩ បានផ្តល់ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដែលតម្រូវឱ្យកម្ពុជាត្រូវការកសាងសមត្ថភាពគ្រប់គ្រងវិបត្តិ ពង្រឹងភាពធន់ និងការសម្របខ្លួនតាមគន្លងប្រក្រតីភាពថ្មីដើម្បីប្រែក្លាយជាកាលានុវត្តភាពក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ឡើងវិញតាមរយៈផែនទីចង្អុលផ្លូវ ស្តីពីផែនការស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិកូវីដ-១៩ (២០២០-២០២៥)។

ការបើកទ្វារទទួលទេសចរអន្តរជាតិមកកាន់កម្ពុជាត្រូវធ្វើឡើងដោយមានផែនការច្បាស់លាស់ និងមានការគ្រប់គ្រងត្រឹមត្រូវដើម្បីធានាបានដំណើរការប្រក្រតីនៃឧស្សាហកម្មទេសចរណ៍ និងសុវត្ថិភាពចំពោះសហគមន៍ និងសង្គម។

ទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោកគឺជាការធ្វើដំណើរពេញនិយមមួយ និងមានភាពទាក់ទាញសម្រាប់ទេសចរអន្តរជាតិក្នុងរយៈចម្ងាយខ្លី និងមធ្យម ជាពិសេសទេសចរមកពីបណ្តាប្រទេសជិតខាង និងប្រទេសក្នុងតំបន់។

នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាសម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក នៅក្នុងដំណាក់កាលនៃការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ត្រូវបានរៀបចំឡើងដើម្បីផ្តល់ប្រយោជន៍ជាត្រីវិស័យបង្ហាញពីលក្ខខណ្ឌ និងគោលការណ៍ប្រតិបត្តិសំខាន់ៗ ដែលទេសចរបើកបរដោយខ្លួនឯងតាមផ្លូវគោកត្រូវអនុវត្ត និងបង្ហាញពីកិច្ចសហការរវាងស្ថាប័នរដ្ឋ និងផ្នែកឯកជនដែលជាអ្នកពាក់ព័ន្ធចូលរួមអនុវត្តដើម្បីធានាបានដំណើរទេសចរណ៍មួយដែលមានសុវត្ថិភាព និងភាពរីករាយ និងមិនមានហានិភ័យដល់សហគមន៍ក៏ដូចជាឧស្សាហកម្មទេសចរណ៍ទាំងមូល។

**២. និយមន័យទេសចរបើកបរដោយខ្លួនឯង**

ទេសចរបើកបរដោយខ្លួនឯង សំដៅលើដំណើរទេសចរណ៍របស់ទេសចរអន្តរជាតិ ជាលក្ខណៈបុគ្គល គ្រួសារ ឬជាក្រុម ចូលមកព្រះរាជាណាចក្រកម្ពុជាតាមរយៈមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ឬជួល។

**៣. គោលបំណង និងវិសាលភាព**

**៣.១. គោលបំណង**

ដើម្បីធានាបានការធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោកមួយ ដែលមានការសម្របសម្រួល ការគ្រប់គ្រង និងកិច្ចសហការល្អ ក្នុងន័យរក្សាបាននូវភាពជឿទុកចិត្ត និងទំនុកចិត្តគ្នាទៅវិញទៅមក ពោលគឺ **"ទេសចរមានសុវត្ថិភាព សហគមន៍ទេសចរណ៍រុងរឿង"** នីតិវិធីប្រតិបត្តិនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងដូចខាងក្រោម៖

- ផ្សព្វផ្សាយពីគោលដៅទេសចរណ៍ដើម្បីទាក់ទាញ និងជំរុញកំណើនទេសចរតាមផ្លូវគោក
- កំណត់គោលការណ៍ និងលក្ខខណ្ឌដើម្បីសម្រួលដល់ការធ្វើដំណើរ និងផ្តល់បទពិសោធន៍ល្អៗសម្រាប់ទេសចរបើកបរដោយខ្លួនឯង
- ពង្រីកឱកាសសម្រាប់ផ្នែកឯកជនក្នុងការផ្តល់សេវាកម្មទេសចរណ៍

➢ ជានាបានការគ្រប់គ្រងដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក និងពង្រឹងសមត្ថភាពឆ្លើយតបទាន់ពេលវេលាចំពោះហេតុការណ៍ ឬហានិភ័យណាមួយដល់ទេសចរ ក៏ដូចជាគោលដៅទេសចរណ៍ និងសហគមន៍។

### ៣.២. វិសាលភាព

នីតិវិធីប្រតិបត្តិស្តង់ដានេះមានវិសាលភាពអនុវត្តសម្រាប់ការធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤. បញ្ញត្តិទូទៅនៃការយកមធ្យោបាយធ្វើដំណើរចូលបណ្តោះអាសន្ន និងចេញទៅវិញ

### ៤.១. ការអនុញ្ញាត

រាជរដ្ឋាភិបាលកម្ពុជាបានបង្កលក្ខណៈងាយស្រួល និងអនុញ្ញាតឱ្យទេសចរអាចយកចូលបណ្តោះអាសន្ន និងចេញទៅវិញនូវមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ក្នុងអំឡុងពេលធ្វើដំណើរទេសចរណ៍មកកាន់ព្រះរាជាណាចក្រកម្ពុជា។

### ៤.២. រយៈពេលកំណត់

ទេសចរត្រូវបានអនុញ្ញាតឲ្យយកមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនចូលបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ដំណើរទេសចរណ៍ ស្របតាមទិដ្ឋាការប្រភេទទេសចរ ឬការអនុញ្ញាតរបស់សមត្ថកិច្ចនគរបាលអន្តោប្រវេសន៍ ដោយមានរយៈពេលយ៉ាងយូរចំនួន ៣០ថ្ងៃ។

យោងតាមមាត្រាទី១៤ នៃអនុក្រឹត្យលេខ ១២៣ អនក្រ.បក. ស្តីពី បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសដែលទទួលបានទិដ្ឋាការប្រភេទទេសចរចូលក្នុងព្រះរាជាណាចក្រកម្ពុជាអាចស្នាក់នៅរយៈពេល ១(មួយ)ខែ។

### ៤.៣. ការពន្យារពេលចេញទៅវិញ

ក្នុងករណីមានការពន្យារពេលនៃការចេញទៅវិញ ម្ចាស់មធ្យោបាយធ្វើដំណើរ ឬតំណាងត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ការពន្យារពេលនៃការចេញទៅវិញ អាចត្រូវបានអនុញ្ញាតបន្ថែមយ៉ាងយូរចំនួន ៣០ថ្ងៃ។

យោងតាមមាត្រាទី១៩ នៃអនុក្រឹត្យលេខ ១២៣ អនក្រ.បក. ស្តីពី បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នសម្រាប់ទិដ្ឋាការប្រភេទទេសចរ អាចបន្តរយៈពេលបាន ១(មួយ)ខែ តែម្តងគត់។

### ៤.៤. ការពិន័យ

យោងតាមសារាចរណែនាំលេខ០១៤ ស.ហ.វ. របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ ការហួសសុពលភាពនៃការចេញទៅវិញនឹងត្រូវរងការពិន័យក្នុង **មួយថ្ងៃ** ចំនួន ១០.០០០(មួយម៉ឺន) រៀល សម្រាប់ទោចក្រយាន ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់ទោចក្រយានយន្ត និងចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល សម្រាប់មធ្យោបាយធ្វើដំណើរផ្សេងទៀត ដែលអនុវត្តដោយមន្ត្រីគយមានសមត្ថកិច្ចនៅច្រកចេញ។

### ៤.៥. លក្ខខណ្ឌនៃការប្រើប្រាស់

ទេសចរអាចប្រើប្រាស់មធ្យោបាយធ្វើដំណើរ ក្នុងគោលបំណងបម្រើឲ្យការធ្វើដំណើរទេសចរណ៍របស់ខ្លួនតែ

ប៉ុណ្ណោះ និងមិនអនុញ្ញាតឲ្យប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួននេះសម្រាប់ការធ្វើអាជីវកម្ម ឬបម្រើសេវាកម្មផ្សេងៗឡើយ។

## ៥. ភារកិច្ចរបស់ទេសចរបើកបរដោយខ្លួនឯង

### ៥.១. ការបំពេញលក្ខខណ្ឌសម្រាប់សមត្ថកិច្ចគយ

#### ៥.១.១. តម្រូវការឯកសារចាំបាច់សម្រាប់មធ្យោបាយធ្វើដំណើរ

ដើម្បីទទួលបានការអនុញ្ញាតឲ្យយកមធ្យោបាយធ្វើដំណើរចូលបណ្ដោះអាសន្នបាន ទេសចរបើកបរដោយខ្លួនឯងត្រូវមានឯកសារច្បាប់ដើម និងចម្លងដូចខាងក្រោម៖

- លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរផ្សេងៗមានតម្លៃស្មើ
- បណ្ណសម្គាល់មធ្យោបាយធ្វើដំណើរ សៀវភៅ ATA Carnet ឬបណ្ណសម្គាល់ប្រហាក់ប្រហែល (លើកលែងទោចក្រយាន)
- បណ្ណបើកបរយានយន្ត
- បណ្ណធានារ៉ាប់រងស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (បច្ចុប្បន្ននេះ តម្រូវការបណ្ណធានារ៉ាប់រងត្រូវបានលើកលែងជាបណ្ដោះអាសន្ន)
- ឯកសារពាក់ព័ន្ធចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសចេញដំណើរចុងក្រោយ
- ឯកសារតម្រូវនានាដោយសមត្ថកិច្ចកម្ពុជា

#### ៥.១.២. ការស្នើសុំយកចូលបណ្ដោះអាសន្ន

ទេសចរដែលជាម្ចាស់មធ្យោបាយធ្វើដំណើរត្រូវបំពេញប្រតិវេទន៍គយជាមុនតាមប្រព័ន្ធអនឡាញ (www.customs.gov.kh => "យានយន្តចេញចូលបណ្ដោះអាសន្ន/Temporary Vehicle") ឬត្រូវបំពេញក្នុងពេលមកដល់ច្រកទ្វារព្រំដែនអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជានៅនឹងការិយាល័យគយប្រចាំនៅច្រកទ្វារ។

#### ៥.១.៣. ការរក្សាទុកប្រតិវេទន៍គយ

នៅពេលទទួលបានការអនុញ្ញាត មន្ត្រីគយមានសមត្ថកិច្ចនឹងប្រគល់នូវប្រតិវេទន៍គយជូនម្ចាស់មធ្យោបាយធ្វើដំណើរ ដើម្បីមានសិទ្ធិក្នុងការយកមធ្យោបាយធ្វើដំណើរចូលបណ្ដោះអាសន្ន។

ក្នុងរយៈពេលស្នាក់នៅបណ្ដោះអាសន្ននៅកម្ពុជា ម្ចាស់មធ្យោបាយធ្វើដំណើរត្រូវរក្សាប្រតិវេទន៍គយសម្រាប់ការត្រួតពិនិត្យអនុលោមភាពរបស់មន្ត្រីមានសមត្ថកិច្ចជាយថាហេតុ។ ប្រសិនបើម្ចាស់មធ្យោបាយធ្វើដំណើរមិនគោរពតាមការណែនាំនេះទេ នឹងត្រូវទទួលរងនូវការពិន័យតាមច្បាប់ជាធរមាន។

#### ៥.១.៤. ការចេញទៅវិញ

នៅពេលធ្វើដំណើរចេញត្រឡប់ទៅវិញ ម្ចាស់មធ្យោបាយធ្វើដំណើរត្រូវប្រគល់ប្រតិវេទន៍គយជូនមន្ត្រីគយមានសមត្ថកិច្ចដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិដែលត្រូវចេញទៅវិញ។

ក្នុងករណីមានតម្រូវការប្ដូរច្រកចេញ ម្ចាស់មធ្យោបាយធ្វើដំណើរ ឬតំណាងត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ សំណើសុំប្ដូរច្រកចេញ ឬពន្យារពេលនៃការចេញទៅវិញ អាចធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ។

### ៥.២. ការបំពេញលក្ខខណ្ឌសម្រាប់ការចូល-ចេញ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ដើម្បីទទួលបានការអនុញ្ញាតឲ្យចូល ចេញ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាពីសមត្ថកិច្ចអន្តោប្រវេសន៍ ទេសចរត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរផ្សេងៗមានតម្លៃស្មើ ដែលត្រូវមានសុពលភាពយ៉ាងតិច ៦(ប្រាំមួយ)ខែ
- មានទិដ្ឋាការដែលមានសុពលភាព ចេញដោយស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលកិត្តិយសនៅក្រៅប្រទេស ឬតាមរយៈការស្នើសុំតាមអនឡាញ www.evisa.gov.kh ឬតាមការស្នើសុំ **ទិដ្ឋាការពេលមកដល់ (Visa on arrival)** ឬក៏តាមវិធីផ្សេងទៀតដែលបានកំណត់ លើកលែងតែទេសចរដែលកាន់លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរមានតម្លៃស្មើរបស់ប្រទេសដែលបានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការជាមួយព្រះរាជាណាចក្រកម្ពុជា
- ករណីទេសចរមានបំណងស្នាក់នៅលើសពីរយៈពេលកំណត់ខាងលើ នោះត្រូវស្នើសុំបន្តរយៈពេលស្នាក់នៅពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ ការស្នើសុំបន្តរយៈពេលស្នាក់នៅត្រូវបានអនុញ្ញាតបន្ថែម ១(មួយ)ខែ លើកលែងតែទេសចរប្រើប្រាស់ទិដ្ឋាការប្រភេទ T1, T2, T3 ដែលអាចត្រូវបានអនុញ្ញាតបន្ថែម ៣(បី)ខែ ដូចដែលបានកំណត់ក្នុងអនុក្រឹត្យលេខ១២៣អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចូល ចេញ និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ទេសចរដែលស្នាក់នៅហួសរយៈពេលកំណត់ ត្រូវទទួលរងនូវការពិន័យអន្តរការណ៍ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ១២៣អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពី បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចូល ចេញ និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៥.៣. ការអនុវត្តវិធានសុខាភិបាល

លក្ខខណ្ឌសម្រាប់ការអនុវត្តវិធានសុខាភិបាល ទេសចរមិនតម្រូវឲ្យបង្ហាញសេចក្តីប្រកាសសុខភាព និងបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញនៅពេលមកដល់កម្ពុជាឡើយ ប៉ុន្តែទេសចរត្រូវធ្វើតាមការណែនាំរបស់មន្ត្រីចត្តាឡីស័កក្នុងករណីចាំបាច់ណាមួយ។

### ៥.៤. ការអនុវត្តវិធានណែនាំនានាក្នុងពេលធ្វើដំណើរទេសចរណ៍

ក្នុងពេលធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទេសចរត្រូវប្រកាន់ខ្ជាប់កិច្ចសហការល្អ និងអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងវិធានណែនាំដែលដាក់ចេញដោយអាជ្ញាធរសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន និងគោលដៅទេសចរណ៍នានា រួមទាំងវិធានណែនាំសំខាន់ៗ ដូចខាងក្រោម៖

- វិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមានានា
- ត្រូវអនុវត្តតាមច្បាប់ចរាចរណ៍ និងការណែនាំនានាអំពីការបើកបរក្នុងព្រះរាជាណាចក្រកម្ពុជា
- ត្រូវអនុវត្តវិធានសុខាភិបាល
- ត្រូវអនុវត្តតាមគោលការណ៍គួរធ្វើ និងមិនគួរធ្វើសម្រាប់ទេសចរវ៉ាក់សាំងគម្រោងក្នុងប្រទេសកម្ពុជា

- យោងតាមមាត្រាទី៥០ នៃច្បាប់ស្តីពីទេសចរណ៍ ទេសចរ ឬអ្នកធ្វើដំណើរកម្សាន្តត្រូវមានកាតព្វកិច្ចដូចតទៅ៖
    1. ត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា
    2. គោរពប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ខ្មែរ និងមិនត្រូវចូលរួមក្នុងសកម្មភាពណាដែលបំពាន ឬធ្វើឲ្យប៉ះពាល់ដល់វប្បធម៌ខ្មែរ
    3. មិនត្រូវធ្វើឲ្យខូចខាតដល់បរិស្ថាន ឬមរតកវប្បធម៌ និងមរតកធម្មជាតិ
    4. មិនត្រូវចូលក្នុងសកម្មភាពណាមួយដែលពាក់ព័ន្ធដល់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ការលាងលុយកខ្វក់ និងការបង្កឱ្យមានអសន្តិសុខក្នុងសង្គម
    5. មិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងសុខុមាលភាពជាទូទៅ
    6. មិនត្រូវគំរាមកំហែងដល់សន្តិសុខ ឬជាប់ពាក់ព័ន្ធក្រុមភេរវកម្ម។

### ៥.៥. ការប្រតិបត្តិសំខាន់ៗក្នុងពេលបើកបរ

- ត្រូវបើកបរដោយប្រកាន់ស្តាំ
- ត្រូវគោរពស្លាកសញ្ញា ភ្លើងសញ្ញា និងនគរបាលចរាចរណ៍
- ត្រូវពាក់ខ្សែក្រវាត់ក្នុងពេលបើកបរ
- ក្មេងអាយុក្រោម ១២ឆ្នាំមិនត្រូវបានអនុញ្ញាតឲ្យអង្គុយកៅអីខាងមុខឡើយ
- អ្នកបើកបរមិនត្រូវប្រើទូរស័ព្ទ និងមិនត្រូវបរិភោគគ្រឿងស្រវឹង
- ល្បឿនកំណត់ក្នុងទីប្រជុំ ៤០គីឡូម៉ែត្រ/ម៉ោង ក្រៅទីប្រជុំជន ៦០គីឡូម៉ែត្រ/ម៉ោង និង ៨០គីឡូម៉ែត្រ/ម៉ោង
- ស្លាកសញ្ញាកំណត់ល្បឿនមានបញ្ជាក់នៅតាមដងផ្លូវ
- ការបើកបរលើសល្បឿនកំណត់នឹងទទួលការផាកពិន័យពីនគរបាលចរាចរណ៍។

### ៥.៦. លេខទំនាក់ទំនងក្នុងគ្រាអាសន្ន

ក្នុងករណីបញ្ហាចៃដន្យណាមួយកើតឡើងក្នុងពេលធ្វើដំណើរ ទេសចរបើកបរដោយខ្លួនឯងអាចទាក់ទងលេខទូរស័ព្ទដូចខាងក្រោម៖

- លេខរថយន្តសង្គ្រោះបន្ទាន់ 119
- លេខនគរបាលជាតិ 117 / 118

## ៦. គោលដៅទេសចរណ៍ និងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍

នៅក្នុងការធ្វើដំណើរទេសចរណ៍បើកបរដោយខ្លួនឯងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទេសចរត្រូវជ្រើសរើសយកគោលដៅទេសចរណ៍ និងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ដែលអនុវត្តតាមការណែនាំនានាដូចជា៖

- អនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងទទួលបានឡាប៊ែលវិធានសុវត្ថិភាពទេសចរណ៍
- អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាអប្បរមាដែលដាក់ឲ្យអនុវត្តដោយក្រសួងទេសចរណ៍
- អនុវត្តវិធានចាំបាច់នានាដែលបានកំណត់ដោយអាជ្ញាធរសុខាភិបាល

## ៧. សេចក្តីសន្និដ្ឋាន

ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានបើកដំណើរការសេដ្ឋកិច្ច និងសង្គម ព្រមទាំងបើកទ្វារទទួលស្វាគមន៍ទេសចរមកទស្សនាកម្ពុជាឡើងវិញ នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាសម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងបានចូលរួមគាំទ្រយ៉ាងសំខាន់ដល់ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិកូវីដ-១៩ (២០២០-២០២៥) និងផែនការយុទ្ធសាស្ត្រស្តីពី ការបើកទទួលទេសចរណ៍វ៉ាក់សាំង ដោយដើរតួជាចលករក្នុងការទាក់ទាញ និងជំរុញកំណើនទេសចរតាមផ្លូវគោក ព្រមទាំងកសាងទំនុកចិត្ត និងបង្កើនភាពជឿជាក់រវាងទេសចរ និងសហគមន៍ដើម្បីធានាបាននិរន្តរភាពនៃការរីកចម្រើនរបស់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងនៅក្នុងគន្លងប្រក្រតីភាពថ្មី។

## ៨. តារាងសង្ខេបអំពីទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក

**មុនចេញដំណើរ ទេសចរត្រូវមាន**

១. មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនស្របច្បាប់
២. បណ្ណបើកបរ
៣. លិខិតឆ្លងដែន[1]
៤. ទិដ្ឋាការ ឬស្នើសុំទិដ្ឋាការពេលមកដល់ (Visa on Arrival)

↓

**ពេលមកដល់ច្រកទ្វារព្រំដែនអន្តរជាតិ**

↓

**សមត្ថកិច្ចគយ និងរដ្ឋាករកម្ពុជា**
ការស្នើសុំប្រតិវេទន៍គយ (តាមអនឡាញ ឬនៅច្រកទ្វារព្រំដែន)

**សមត្ថកិច្ចអន្តោប្រវេសន៍**
ការស្នើសុំទិដ្ឋាការ[2]

**សមត្ថកិច្ចសុខាភិបាល**
មិនតម្រូវឲ្យបង្ហាញសេចក្តីប្រកាសសុខភាព និងបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ទេ

↓

**ពេលស្នាក់នៅកម្ពុជា**

- គោរពច្បាប់ព្រះរាជាណាចក្រកម្ពុជា
- អនុវត្តវិធានសុវត្ថិភាពទេសចរណ៍
- អនុវត្តវិធានសុខាភិបាល
- ទៅមូលដ្ឋានទេសចរណ៍ដែលមានការទទួលស្គាល់[3]

*សម្គាល់*

[1] លិខិតឆ្លងដែនត្រូវមានសុពលភាពយ៉ាងតិច ៦ខែ

[2] ទិដ្ឋាការដែលមានសុពលភាពចេញដោយស្ថានបេសកកម្មការទូត ឬស្ថានកុងស៊ុល ឬស្ថានកុងស៊ុលកិត្តិយសនៅក្រៅប្រទេស ឬស្នើសុំតាមអនឡាញ ឬស្នើសុំទិដ្ឋាការពេលមកដល់ (Visa on arrival) ឬក៏តាមនីតិវិធីផ្សេងដែលបានកំណត់។

[3] គោលដៅទេសចរណ៍ និងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ដែលបានអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា និងវិធានសុខាភិបាល។

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី